## សិក្សាពិចារណា

# ប្រវត្តិអក្សរសាស្ត្រខ្មែរ



CA30

# ប្រវត្តិ
# អក្សរសាស្ត្រខ្មែរ

ស្រង់ចេញពីកាសែតសាមគ្គី

បោះផ្សាយលើកទី ៤

មិនា ១៩៦១

រក្សាសិទ្ធិ

# អារម្ភកថា

នៅក្រោមនឹមដែកចក្រពត្រអាណានិគមនិយមជិត ១០០ ឆ្នាំ គន្លងទៅហើយ ប្រជាជនយើងស្រីប្រុសត្រូវឃ្លាតចេញឆ្ងាយ ពីវប្បធម៌ជាតិ ពីប្រវត្តិសាស្ត្រជាតិ ត្រូវអាណានិគមនិយម បានបង្ខំឲ្យរៀនភាសាគេ ឲ្យទទួលប្រើអក្សរគេជាផ្លូវការ ឲ្យក្រេបជញ្ជក់នូវវប្បធម៌ចក្រពត្រនិយមពុករលួយ ៗ ដូច្នេះហើយ បានជាយើងច្រើនមានគុណវិបត្តិវណ្ដាតអណ្ដានវិល តាមគេមាក់ងាយភ្លេចកេរ្តិ៍ដំណែលស្នាដៃ ប្រជាជនខ្មែរយើង មានសិល្បអក្សរសាស្ត្រជាដើម ៗ

ចាប់តាំងពីលេខមួយរៀងរហូតមកទល់នឹងថ្ងៃឈប់កា-សែត «សាមគ្គី» បានទីវែកញែកដោះស្រាយបញ្ហានយោបាយ សេដ្ឋកិច្ច, សង្គមកិច្ច, វប្បធម៌, កីឡា ជូនបងប្អូនពិចារណា ៗ

ដើម្បីជាប្រយោជន៍ដល់បងប្អូនរួមជាតិ គ្រប់ជាន់ថ្នាក់ ដើម្បីជួយបង្កើនសៀវភៅសិក្សាពិចារណា, យើងខ្ញុំសូម

ប្រមូលគក្កបទ «អក្សរសាស្ត្រខ្មែរ» បង់ជាសៀវភៅ ។

សូមបងប្អូនរួមជាតិជួយពិនិត្យពិចារណានូវឯកសារនេះ ។

មិនា ១៩៥៦

អតីតភ្នាក់ងារកាសែតសាមគ្គី

ខឹម–សំ ឌុ

# ប្រវត្តិកំណើតអក្សរសាស្ត្រ

មនុស្សលោកកាលពីជាន់ដើមប្រកបរបររកស៊ីផ្អែកនៅលើធម្មជាតិហើយប្រើកម្លាំងផ្ទាល់មានបរបាញ់ នេសាទនឹងដាំដំណាំបន្តិចបន្តួចគ្រប់គ្រាន់តែចិញ្ចឹមគ្រួសារខ្លួន, កុលសម្ព័ន្ធខ្លួនប៉ុណ្ណោះ ៗ សកម្មភាពក្នុងសង្គមជំនាន់នោះមានតិចតួចស្តួចស្តើងជាអនេក ៗ ម្ល៉ោះហើយ ការទាក់ទងរវាងក្រុមនឹងរវាងកុលសម្ព័ន្ធក៏មិនសូវជាស្មុគស្មាញប៉ុន្មានដែរ គ្រាន់តែនិយាយនឹងសំដីរកគ្នាទៅវិញទៅមកក៏ជាការស្រេច ៗ ក៏ប៉ុន្តែដល់កុលសម្ព័ន្ធដុះដាលរីកធំឡើង, សកម្មភាពក្នុងសង្គមក៏បែកសាយជាច្រើនសណ្ឋានឡើង ឯការទាក់ទងរវាងមនុស្សនឹងមនុស្ស រវាងក្រុមនឹងក្រុមក៏រឹតតែមានសភាពធំទូលាយឡើង

ម្ល៉ោះហើយការនិយាយដោយសំដីសុទ្ធ ៗ ឃើញថាមិនគ្រប់គ្រាន់នឹងបំពេញសកម្មភាពក្នុងសង្គមបាន ។

ហេតុដូច្នេះ មនុស្សងាកទៅរកគំនូសនិងសញ្ញាផ្សេង ៗ ដើម្បីសំគាល់របស់របរសព្វសារពើ ដើម្បីកត់ចំណាំទុកនូវរបៀបប្រើប្រាស់គ្រឿងផលិតកម្មផ្សេង ៗ ដើម្បីទុកដំណែលឲ្យកូនចៅរបស់ខ្លួននូវឧត្តមគតិ,លទ្ធិគ្រប់ចំពូក ។ល។ តមកទៀតជីវភាពមនុស្សកាន់តែសាំញ៉ាំឡើង ។ សង្គមកាន់តែមានវឌ្ឍនធម៌ចំរើនលឿនទៅមុខផងអនេក ធ្វើឲ្យគំនូសសញ្ញាទាំងឡាយ ដែលពីដើមគ្រាន់តែជាបុព្វហេតុមធ្យោបាយ ក៏-ឡើងប្រែក្លាយទៅជាអក្សរ រួចក៏មាន ផ្លែផ្កាជាអក្សរសាស្ត្រដូចយើងសព្វថ្ងៃ ។

អក្សរសាស្ត្រជាមែកធាងនៃវប្បធម៌ ។ ដូចសិល្បក្ដីប៉ុន្តែទាំងពួង អក្សរសាស្ត្រអាចឲ្យយើងឆ្លុះមើលឃើញការរស់នៅក្នុងសង្គមមនុស្សក្នុងរយៈណាមួយ ។

**អក្សរសាស្ត្រមិនមានចរិតដូចគ្នាទាំងអស់ទេ គឺជាប់នឹង**

សង្គម ៗដូច្នេះ អក្សរសាស្ត្រត្រូវប្រែប្រួលទៅតាមការវិវត្តន៍សង្គមនៃមនុស្សជាដាច់ខាត ។

សង្គមសក្តិភូមិ មានអក្សរសាស្ត្ររបស់គេៗអត្ថសេរអក្សរសាស្ត្រនោះ ច្រើនផ្អែកទៅលើសាសនា ច្រើនផ្អែកលើបុគ្គលមួយរូបៗដែលគេច្រើនលើកតម្កើង ជាតំណាង «អាទិទេព» តំណាង «ព្រះឥន្ទ្រ» តំណាង «ព្រះម្ចាស់សួគ៌» តំណាង «ព្រះពោធិសត្វ» ឬ «ព្រះពុទ្ធ» យកកំណើតក៏មាន ។ គេច្រើនរាប់ថាបុគ្គលនោះគឺជាពូជខ្ពស់ចុះពី «ឋានលើ» មកយកកំណើត ហើយត្រូវមានឥទ្ធិពលបង្ក្រាបជិះជាន់គេបានតាមចិត្ត បាញ់សម្លាប់បានទាំងអស់ គ្មានច្បាប់ឯណាធំជាងបុគ្គលមួយរូបនោះទេ ។ គេនិយាយដូច្នេះ ដើម្បីគេបោកប្រាសប្រជាជនឱ្យសុខចិត្តគោរពកោតខ្លាចចុះចូលដូចសត្វតិរច្ឆាន ។

អក្សរសាស្ត្រសង្គមមូលធននិយម ច្រើនបង្វិលប្រជាជនឱ្យអណ្តែតអណ្តូងយល់ឃើញថា «លោកតាប្រាក់ជាធំគេ» ។ គេបង្កើតបណ្តុះគំនិតដូច្នេះ ព្រោះគេឱ្យប្រជាជនភ្លាំភ្លាយខ្លួន

សុខចិត្តឲ្យគេប្រើរៀងរហូតទៅ ហើយឲ្យយល់ថាមានតែនាយទុនទេ ដែលជាម្ចាស់ធនធានក្នុងសង្គមទាំងអស់ ។

អក្សរសាស្ត្រសង្គមនិយម មានចរិតប្រជាជាតិប្រជាជនទីង វិទ្យាសាស្ត្របានន័យថា ដឹកនាំប្រជាជនឲ្យស្គាល់កម្លាំងរបស់ខ្លួនឲ្យលះបោលនូវជំនឿគ្មានសមហេតុផល ។ អក្សរសាស្ត្រសង្គមនិយមផ្អែកទៅលើវិទ្យាសាស្ត្រ ដែលអាចបង្ហាញមនុស្សឲ្យឃើញការពិតជាក់ស្តែងនិងអាចជួយសម្រាលកម្លាំងមនុស្សក្នុងការបង្កើតផលិតផល ។ល។

ដូចយើងបានឃើញដឹងខ្លះហើយ នៅសង្គមសក្តិភូមិ ឬទុននិយមមានមនុស្សជិះជាន់មនុស្ស ដែលជាបុព្វហេតុធំឲ្យមានវណ្ណៈក្នុងសង្គមនោះប្រឆាំងគ្នា ។ នៅសង្គមសក្តិភូមិការទំនាស់វណ្ណៈ មានកើតឡើងដោយពួកសក្តិភូមិជិះជាន់ពួកកសិករ ដែលទ្រាំមិនបានក៏ប្រឆាំងតបវិញ ។ នៅសង្គមទុននិយម ការទំនាស់វណ្ណៈកើតឡើងដោយពួកនាយទុន (គ្នាតិច) ជិះជាន់សង្កត់សង្កិនពួកអធនមានកម្មករ កសិករ

(គ្នាច្រើន) ៗ ការចំលាស់វណ្ណៈនេះហើយ ដែលជាមូលហេតុមួយធំ ជម្រុលសង្គមមនុស្សអោយឡើងទៅសង្គមជឿនលឿន ដូចជាមានការបដិវត្តន៍ប្រជាជនកសិករវាយរំលោយរបបសក្តិភូមិ ហើយទឹងកម្មករកសិករវាយរំលោយរបបមូលនិយមចោល ហើយតាំងរបបសង្គមនិយមថ្មី ៗ ការចំលាស់វណ្ណៈនេះ បានបញ្ចាំងក្នុងអក្សរសាស្ត្រ ៗ គេអាចឃើញក្នុងសង្គមមូលនិយមនឹងសង្គមសក្តិភូមិ មានអក្សរសាស្ត្រពីរយ៉ាង ប្រឆាំងគ្នាបំរើវណ្ណៈរៀងខ្លួន អក្សរសាស្ត្រជឿនលឿនបដិវត្តន៍ នឹងអក្សរសាស្ត្របដិកិរិយា ៗ

**អក្សរសាស្ត្រជឿនលឿនបដិវត្តន៍**– អក្សរសាស្ត្រនេះ ច្រើនកើតឡើងសម្រាប់ប្រជាជនហើយមិនបានចងក្រងជាសៀវភៅទេ ច្រើនតែនិយាយគ្នាពីមាត់មួយទៅមាត់មួយ ៗ រឿងនេះកើតឡើងដុះពីទ្រូងប្រជាជន ហើយនិយាយតពីមាត់មួយទៅមាត់មួយរកម្ចាស់ដើមមិនឃើញឡើយៗ យ៉ាង

ទៀតអ្នកកាន់អំណាចនៅសម័យនោះ មិនបានយកចិត្តទុកដាក់ទំនងតារ ឬបោះពុម្ពទុកជាសាស្ត្រាឲ្យប្រជាជនរៀន ដឹងឮគ្រប់គ្នាទេ ផ្ទុយទៅវិញ គេរកតែបំបាត់ចោលឲ្យសូន្យឈឹងៗ

**អក្សរសាស្ត្របដិកិរិយា—** អក្សរសាស្ត្រនេះបំរើវណ្ណៈខ្លាំងពូកែជិះជាន់គេក្នុងសង្គមមនុស្សជិះជាន់មនុស្ស ៗ វណ្ណៈកាន់អំណាចសុទ្ធតែមានគ្រោងការណ៍ បណ្តុះឲ្យពួកគេបំរើខ្លួន តែងចងជាច្បាប់ ជាសៀវភៅសាស្ត្រាមានមុខងារជំតម្កើងក្រុមខ្លួន ៗ គេបោះពុម្ព គេតារ គេដាក់កម្មវិធីឲ្យប្រជាជនរៀនទន្ទេញប្រតិបត្តិតាម ៗ គេបញ្ចូលទៅក្នុងក្បាលប្រជាជនតែអក្សរសាស្ត្រ បំរើវណ្ណៈខ្លាំងពូកែជិះជាន់គេ តាំងពីកុមាររហូតដល់ចាស់ស្លាប់ ៗ ក្នុងសាលារៀនក្នុងវត្ត គេយកតែរឿងអក្សរសាស្ត្រនៃវណ្ណៈ នៃក្រុមគេទៅបញ្ចូលទៅផ្សាយ ៗ

ចំពោះអក្សរសាស្ត្រខ្មែរ ដែលយើងត្រូវវែកញែករៀននៅខាងមុខនេះ យើងនឹងពិនិត្យតាមរបៀបខាងលើ ដែល

យើងបានឆ្លុះមើលអក្សរសាស្ត្រទូទៅ ក្នុងលំនាំដើមនេះ ។ យើងសូមបងប្អូនអ្នកអានសៀវភៅយើង ជួយជ្រោមជ្រែង ទិទៀនអត្ថបទយើងនឹងកែតម្រូវឱ្យផង ក្នុងការពិនិត្យរៀនអក្សរសាស្ត្រខ្មែរនេះ ។

—oo—

# អក្សរសាស្ត្រខ្មែរ

យើងបាននិយាយក្នុងលំនាំដើមថា អក្សរសាស្ត្រប្រែប្រួលជាប់ទៅតាមការវិវត្តន៍សង្គមជានិច្ច ។ ហេតុនេះ ដើម្បីពិនិត្យមើលឲ្យស្គាល់ច្បាស់ តើអក្សរសាស្ត្រយើងមានប្រវត្តិដូចម្ដេចខ្លះ យើងត្រូវស្គាល់ប្រវត្តិសង្គមយើងជាមុនសិន ។

កាលឆ្នាំ ១៨៦៣ ពេលដែលបារាំងដាក់ប្រទេសយើងជាប្រទេសចំណុះ សង្គមខ្មែរយើងជាសង្គមសក្តិភូមិបានកំ-ផែលទាសភាព(ដូចមានទិញលក់មនុស្សជាដើម) នឹងកំផែលកុលសម្ពន្ធ (រស់នៅជាគ្រួសារដោយត្រកូលដូចគ្នា) ។ របបគ្រប់គ្រងដែនដីសម្បូណ៌ាញាសិទ្ធិរាជបានន័យថា «ព្រះរាជាទទួលអំណាចគ្រប់ចំពូកពីទេវស្ថាន»។ប្រជាជនគ្មានសិទ្ធិសេរីភាព ។

សង្គមខ្មែរយើងជាន់នោះ មានចែកជាវណ្ណៈខត្តិយៈ,ព្រាហ្មណ៍ ពួកព្រៃងារ, ពួកអ្នកងារ ដូចមានពន្យល់ក្នុងវចនានុក្រមជាក៏ស្គាល់ស្រាប់ ៗ ដូច្នេះ គេអាចសង្កេតឃើញក្នុងសង្គមខ្មែរមានមនុស្សពីរក្រុមធំ ៗ បណ្ដាអ្នកធំមានអំណាចបង្កើតទំនៀមទម្លាប់ច្បាប់សម្រាប់ក្រុមខ្លួន ហើយដាក់បង្ខំឲ្យប្រជាជនធ្វើតាមគោរពទំនៀមទម្លាប់ទាំងនោះ ។

ក្រោយឆ្នាំ ១៨៦៣ ចក្រពត្តិបារាំង បានចូលដាក់ប្រ-ទេសយើងជាចំណុះ ។ គេផ្អែកទៅលើរបបសក្តិភូមិ ។ គេមកជិះជាន់ប្រជាជនយើងគ្រប់ជាន់ថ្នាក់ ។ សង្គមខ្មែរយើងមិនបានប្រែប្រួលអ្វីប៉ុន្មានទេ ពិតមែនតែមានច្បាប់ខ្លះបំបាត់វណ្ណៈអ្នកងារ ។ ក្នុងរយៈចំណុះបារាំងរៀងរហូតមកដល់ឆ្នាំ១៩៤៧ សង្គមខ្មែរយើង នៅតែជារបបសម្បូរណាជ្ញាសិទ្ធិរាជដដែល ហើយប្រកបរបបអាណានិគមនិយមបារាំងសង្គ្រប់ពីលើផង ។

ក្រោយសង្គ្រាមលោកលើកទីពីរ ១៩៤៥ លទ្ធិប្រជាធិ-បតេយ្យ បានរះហៀរហូរចូលមកប្រទេសខ្មែរយើង ក៏ដូចជា

បានជ្រាបចូលទៅប្រទេសចំណុះផ្សេង ៗ ទៀតដែរ ។ ប្រជាជាតិខ្មែរជាដាច់ខាត ត្រូវអនុវត្តទៅតាមរបបថ្មីនេះ ។ ប្រវត្តិសាស្ត្រប្រែប្រួលរបបគ្រប់គ្រងនេះ មាននៅក្នុងសុន្ទរកថាលោក អៀវ-កើស ប្រធានរដ្ឋសភានៅថ្ងៃ ២១ តុលា ១៩៤៦ ដូចតទៅនេះ :

«ថ្ងៃ ២១ តុលា គ.ស. ១៩៤៦ នេះ ជាវរតិថិជ័យមង្គលមួយ ក្នុងប្រវត្តិសាស្ត្ររបស់ជាតិខ្មែរយើងប្រពៃ ជាទីចងចាំក្នុងសន្តានចិត្តយើងទាំងឡាយ ទៅថ្ងៃក្រោយជាយូរអង្វែង ។

ការប្រែប្រួលរបបគ្រប់គ្រងទៅតាមកាលៈទេសៈ រមែងនាំវឌ្ឍនធម៌គឺសេចក្តីចំរើនមកឲ្យប្រជាជាតិដោយពិតប្រាកដ ។

ប៉ុន្តែក្នុងប្រទេសចំនួនច្រើន ទំរាំកែប្រែរបបគ្រប់គ្រងបាន ក៏តោងមានការបដិវត្តន៍ ដែលសម្រេចទៅបានដោយសន្តិវិធីជាការកម្រក្រៃលែង ការកែរបៀបគ្រប់គ្រងរមែងបានមកដោយប្រើកម្លាំង» ។

នៅថ្ងៃនោះព្រះករុណានរោត្តម-សីហនុ បានថ្លែងតបទៅលោកអៀវ-កើស វិញ នាំឲ្យយើងដឹងច្បាស់នូវបឋមសម្បុណ៌ាជាសិទ្ធិកជ :

«តាំងពីច្រើនសតវត្សមកហើយ ច្បាប់សម្រាប់ប្រទេសខ្មែរ គឺជាច្បាប់សម្បុណ៌ាជាសិទ្ធិកជ ដែលព្រះរាជាទទួលអំណាចគ្រប់ចំពូកអំពីទេវស្ថាន ច្បាប់របៀបបុកណានេះបណ្ដាជនជាតិខ្មែរទទួលប្រតិបត្តិពីដើមរៀងមក ។

ប៉ុន្តែសង្គ្រាមក្នុងសាកលលោក ដែលផុតរលត់ទៅក្នុងឆ្នាំ ១៩៤៥ នេះ ដោយប្រជាធិបតេយ្យបានជ័យជំនះយ៉ាងមហិបូណ៌ា នាំឲ្យមានកម្រៃផ្លាស់គោលការក់ធំៗ ខ្លះ ដែលអស់លោកជាមុខប្រធានរបស់ជាតិសហព័ន្ធ គាត់តែងឡើងក្នុងគ្រាចលាចល ហើយដែលអស់លោកទាំងនេះ បានផ្សាយដល់សាកលលោក ហើយបាចកប់ច្រើនលើកក្នុងចំណោមនានាជាតិមកប្រជុំគ្នា ។

ប្រទេសកម្ពុជាទីងនៅក្រៅអំពីគំនិតថ្មីនេះមិនបាន ។

ហេតុដូច្នេះ ត្រូវខ្ញុំជាម្ចាស់ផែនដី ឲ្យបណ្ដាស្ត្រីមាន រដ្ឋធម្មនុញ្ញជាបឋម ដោយខ្លួនខ្ញុំតាមបែបផែនធូរទូលាយ នឹងសេរីភាពដល់បណ្ដាស្ត្រី ដើម្បីនឹងកែប្រែសម្បូណាញ សិទ្ធិភព ដែលព្រះរាជាទទួលអំណាចពីទេវស្ថាន ទៅជារាជា ធិបតេយ្យមានរដ្ឋធម្មនុញ្ញ ៗ ក្នុងការកាត់តែងព្រះរាជក្រមធំសំខាន់យ៉ាងនេះ ខ្ញុំចង់ចិត្តថាគួរតែហៅបណ្ដាស្ត្រីអ្នកមានវិជ្ជាក្នុងព្រះនគរ តែងច្បាប់រដ្ឋធម្មនុញ្ញនេះ ហើយសួរយោបល់អ្នកតំណាងស្ត្រី មុននឹងសម្រេចសេចក្ដីជាដាច់ខាត ,, ៗ

តពីនោះមក ប្រជាជនខ្មែរ ក៏មានរដ្ឋធម្មនុញ្ញ ១៩៤៧ តែការអនុវត្តន៍តាមច្បាប់រដ្ឋធម្មនុញ្ញ ពុំដែលបានពេញលេញឡើយ ព្រោះពួកអាណានិគមបារាំង ដោយបានម្ញា ពីចក្រពត្រអាមេរិកាំង បានប្រើគ្រប់វិធីបង្កើតឧបសគ្គក្នុងប្រទេសយើង ហើយបំផ្លាញកុំឲ្យយើងទទួលផលជាក់ស្ដែងមានសិទ្ធិសេរីភាព ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនោះ ។

ការបែងចែកវណ្ណៈក្នុងសង្គមយើង បានផ្ដល់ឲ្យមានការបែកយោបល់ បែកពាក្យភាសា បញ្ជាក់យ៉ាងច្បាស់លាស់ក្នុងអក្សរសាស្ត្រខ្មែរយើង ។ យើងបានដឹងគ្រប់គ្នាថាមានពាក្យខ្មែរច្រើនបានន័យតែមួយ ព្រោះពាក្យទាំងនោះច្រើនប្រើសម្រាប់ក្រុមវណ្ណៈរបស់ខ្លួន ។

ឧទាហរណ៍.—

ស្ដេចយាង, លោកសង្ឃនិមន្ត, ពូដើរ, កូនដើរ, នាងដើរ ។
ស្ដេចផ្ទំ, លោកសង្ឃសឹង, ពូសម្រាន្ត, កូនដេក, អានាងគេង ។
ស្ដេចសោយ, លោកសង្ឃឆាន់, ពូពិសា, កូនស៊ី, អានាងញ៉ាំ ។

យាង, សោយ, ផ្ទំ,. ជារាជសព្ទ បានន័យថា ប្រើបានតែក្នុងឋានៈសម្រាប់ដំកើងរាជវង្សានុវង្ស ។

និមន្ត, សឹង, ឆាន់: ជាពាក្យសង្ឃ ។ ការប្រើពាក្យនេះបានតែជាមួយសង្ឃ ។ យើងត្រូវយល់ឲ្យជាក់ថា ការទាក់ទងជាមួយព្រះសង្ឃនិងព្រះរាជា ប្រជាជនត្រូវបង្ខំប្រើអាកប្បកិរិយាលុតក្រាបដើរទាស្រដៀងគ្នា ។

ដើរ ពីសា សម្រាន្ត ស៊ី ដេក ... ជាពាក្យប្រជាជនពិតប្រាកដ ៗ ការនិយាយកាន់គ្នាមានសភាពស្មើគ្នា ៗ

គេនឹង ញ៉ាំ ជាពាក្យក្រុងសម្រាប់និយាយទៅកាន់កូនក្មេង ៗ ពាក្យនេះជាពាក្យថ្នម ៗ ពាក្យនេះបានផ្សាយជ្រាបទៅដល់ស្រែចំការខ្លះហើយ ៗ

ការបែងចែកពាក្យទៅតាមថ្នាក់តាមវណ្ណៈនេះ មានពិតប្រាកដគ្រប់សង្គមសក្តិភូមិក្នុងលោក ៗ ប្រវត្តិសាស្ត្របានបង្ហាញមកថា ក្រោយពេលដែលសង្គមណាមួយរលត់ ពាក្យសម្រាប់សង្គមនោះ អាកប្បកិរិយាសម្រាប់សង្គមនោះ ក៏រលត់ទៅជាមួយដែរ ៗ នៅស្រុកបារាំងក្រោយការបដិវត្តន៍១៧៨៩ សង្គមទុនទិយម បានបំបាត់ពាក្យឋានន្តរសក្តិរបស់សក្តិភូមិចោល ហើយការទាក់ទងរវាងប្រជាជនទាហ៊ឹនមកត្រឹមពាក្យហៅគ្នាទៅវិញទៅមកថា «លោក អ្នក» ៗ អាកប្បកិរិយាទំនៀមទម្លាប់លុតក្រាបក្នុងសក្តិភូមិ ក៏បានរលាយទៅជាមួយដែរ ៗ ប្រជាជនច្រើននិយាយទៅកាន់ប្រធានាធិបតីឬនាយក

រដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រីនិយាយកាន់មកវិញតែត្រឹមពាក្យ «លោកនេះលោកនោះ» ៗ ក្នុងស្រុកសង្គមនិយម ដែលប្រជាជនមានវណ្ណៈកម្មករ កសិករ បានធ្វើជាម្ចាស់ ជាចៅហ្វាយនៃនយោបាយ, សេដ្ឋកិច្ច, វប្បធម៌, សង្គមកិច្ច បាននិយមពាក្យទាក់ទងហៅគ្នាទៅវិញទៅមកថា: «សមមិត្ត» (មិត្តស្មើគ្នា) ហើយការលុតក្រាបខ្ពស់ទាបដែលមានក្នុងរបបមុន ក៏បានរលាយរលត់ៗ ប្រជាជនកម្មករស្តីទៅកាន់នាយករដ្ឋមន្ត្រី, ទៅប្រធានាធិបតីហៅថា: «សមមិត្តនាយក» «សមមិត្តប្រធាន» «សមមិត្តស្តាលីន» «សមមិត្ត ម៉ៅ សេ ទុង» ។ល។

ការពិនិត្យមើលប្រវត្តិសង្គមខ្មែរយើង យ៉ាងសើទូខ្លះ អាចផ្តល់ឲ្យយើងចែកអក្សរសាស្ត្រខ្មែរដូចខាងក្រោមនេះ

១–អក្សរសាស្ត្រសម័យអង្គរ

២–អក្សរសាស្ត្រក្រោយសម័យអង្គរធ្វងតាមលង្វែកមកដល់ រជ្ជកាលព្រះអង្គឌួង

៣–អក្សរសាស្ត្រនៅក្រោមនឹមដែកអាណានិគមនិយម

ទំ ។

–អក្សរសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ មក

ដល់សព្វថ្ងៃ ។

–០០០–

# អក្សរសាស្ត្រខ្មែរសម័យអង្គរ

ចាប់តាំងពីមានប្រជាជាតិខ្មែរមកដល់សតវត្សទី ៧ (គ.ស) ខ្មែរយើងមានតែភាសានិយាយមិនទាន់មានអក្សរនៅឡើយ ។ ចាប់តាំងពីសតវត្សទី ៨ (គ.ស) យើងមានអក្សរសរសេរខ្លះ តែមិនទាន់គ្រប់គ្រាន់ ។

អក្សរខ្មែរដំណាក់នោះ ច្រើនជាអក្សរសំស្ក្រឹតលាយចំរុះនិងអក្សរខ្មែរបុរាណ ដែលមានកត់ក្នុងសិលាចារឹកទាំងនោះ (អក្សរចារនៅលើថ្ម) ។ លោកអៃម៉ូនញេ បានមើលអក្សរទាំងនោះរួចមុនគេ ។ ចំពោះអក្សរសិលាចារឹកទាំងនោះលោកស៊ឺដេស . ចាងហ្វាងសាលាបូព៌ាប្រទេសបារាំងបានឲ្យដឹងថា «ភាសាសំស្ក្រឹតជាភាសាអ្នកប្រាជ្ញសម្រាប់ប្រើកត់ត្រា

ធ្វើបញ្ជីព្រះរាជវង្សានុវង្សព្រះមហាក្សត្រ នឹងតែងសេចក្តីសរសើរដល់ក្សត្រដែលទ្រង់សាងប្រាសាទ ឬ អស់លោកដែលមានចិត្តសទ្ធាជ្រះថ្លាធ្វើអំណោយទាន ។ ភាសាមួយទៀតជាភាសាខ្មែរធម្មតា សម្រាប់កត់ត្រាពីរឿងការកសាងនឹងសេចក្តីរៀបរាប់ពួកមនុស្សបំរើនិងគ្រឿងប្រដាប់ប្រដាដែលវេរថ្វាយព្រះវិហារ ។

សេចក្តីតែងជាភាសាសំស្ក្រឹត សុទ្ធតែរៀបរៀងជាពាក្យកាព្យសុទ្ធ គឺជាសេចក្តីចងក្រងឲ្យមានចុងជួនដែលពួកអ្នកសិក្សាអក្សរសាស្ត្រតំណៀហៅថា «កាព្យ» ។

សិលាចារឹកទាំងនោះបានកត់ប្រវត្តិកសាងបុណ្យនៅជួកាលរបស់ស្តេចណាមួយ ។ ក្រៅពីនេះ សម័យអង្គរបានធ្វើឲ្យយើងស្គាល់ចម្លាក់គំនូរដោយចំណងជើងខ្លី ៗ នូវរឿងជាច្រើនដូចជារឿងព្រះរាម, ព្រះវិស្ណុ និងពុទ្ធប្រវត្តិជាដើម ។ ក្នុងចំណុចនេះទៀត លោក ស៊ុដេស បានវែកញែកប្រាប់យើងដូចតទៅនេះ ៖

...រូបចម្លាក់នឹងក្បាច់ចម្លាក់ស្អកស្កុះទុកត ៗ មកនោះ នាំឲ្យយើងយល់ឃើញថា ក្នុងសម័យនោះមុខជាគេបានប្រែរឿងពីបុរាណអស់នោះ ចេញមកជាភាសាអ្នកស្រុកដែរ ៗ មានសិលាចារិកជាច្រើន និយាយទាក់ទងដោយប្រវត្តិរបស់ក្សត្រទាំងឡាយ ព្រមទាំងការត្រួតត្រាព្រះរាជអាណាចក្រខ្មែរសម័យនោះ មិនមែនជាមិនមានប្រើច្បាប់សម្រាប់ស្រុកទេ នឹងមានដល់ទៅសព្វសម្រាប់តុលាការដោយឡែកថែមទៀត ព្រមទាំងវិជ្ជាផ្សេងៗ ដោយមុខៗ របស់ខ្មែរមិនបាច់ពោលថាជាវិទ្យាសាស្ត្រដោយ ក៏គេបានចម្លងទុកជាក្បួនតូច ដូចយើងឃើញមាននៅហូតមកដល់សព្វថ្ងៃ ៗ នៅទីបំផុតពួកអមាត្យាធិបតេយ្យ ដែលធ្វើអង្គររុងរឿងយ៉ាងពន្លឹកដូច្នោះ មិនមែនគ្មានវិញ្ញានធម៌ទេ ឯវិញ្ញានធម៌នោះសោតទៀត ក៏ប្រហែលជាមិនឆ្ងាយចេញតែដោយភាសាសំស្ក្រឹតដែរ ៗ អក្សរសាស្ត្រអស់នេះ មានកើតឡើងជាពិតប្រាកដ ប៉ុន្តែមិនមានសេសសល់ដល់មុខយើងបានសោះឡើយ ដោយហេតុ

សម័យនោះគេប្រើសរសេរគម្រាផ្សេង ៗ ដោយដីសពងលើស្បែកសត្វ ដែលធ្វើឲ្យមានពណ៌ខ្មៅ ម្ល៉ោះហើយគម្រាអស់នោះក៏លប់បាត់អស់ឥតសល់ គឺអន្តរាយដោយអំណាចសត្វល្អិតៗនិងធាតុអាកាស មានតែជាតិថ្មទើបទប់ទល់គង់នៅបាន ៕ ។

យើងបានសង្កេតឃើញតាំងពីសម័យនោះមក អក្សរខ្មែរយើងបានប្រែមានវឌ្ឍនធម៌ចំរើនជាច្រើន ៗ លោកស៊ឺដេស បានឲ្យដឹងថែមទៀតថា:

...វត្តដែលគង់វង្សនៅជាបែបការ្យធម៌សម័យបូកណាខាងសាសនាព្រាហ្មណ៍គឺ:

ក– រឿងរាមកេរ្តិ៍ ដែលជាសេចក្តីប្រែចេញអំពីរឿងរាមាយណៈ ថែមតាំងប្រែមិនបានចប់សព្វគ្រប់ផង ហើយថែមតាំងបំប្រួញជារឿងខ្លី ១ ដែលគេតែងនិយាយលេងជាញឹកញយ ។

ខ– គឺគម្ពីរត្រៃភេទត្រៃភូមិដែលមានដោយដាច់ដោច ។ ។

ដើម្បីនឹងរៀនឲ្យស្គាល់អក្សរសាស្ត្រខ្មែរនៅសម័យអង្គរឲ្យបានជ្រៅជ្រះ ត្រូវតែយើងរៀនឲ្យស្គាល់ឲ្យយល់អក្សរចារឹកថ្មតាំងប៉ុន្មានៗ ថ្មមួយដុំៗ នៅអង្គរមានពាក្យនិយាយប្រាប់យើងច្រើនណាស់ ខាងរបៀបគិតនឹក ខាងរបៀបសិល្បៈ ខាងអក្សរសាស្ត្រទាំងបានបញ្ចេញឲ្យយើងឃើញថា „ខ្មែរ" ដែលជាដីដូនជីតាយើង ខតស៊ូស៊ិតស្ងាញយ៉ាងអស្ចារ្យៗ ត្រូវតែយើងតាំងអស់គ្នាយកតម្រាប់ស៊ិតស្ងាញ ខំពុះពារឧបសគ្គដែលបក្រកពត្រគាមេរកាំងបង្កើតឡើងតាំងប៉ុន្មាន ៗ យើងត្រូវបេជ្ញាការពារសន្តិភាពឯករាជ្យប្រជាធិបតេយ្យ ដើម្បីយើងលំអការរស់នៅរបស់យើងឲ្យមានសិល្បៈ អក្សរសាស្ត្រយុត្តិធម៌ពិតប្រាកដ ។

## អក្សរសាស្ត្រខ្មែរ ក្រោយសម័យអង្គរធ្លង តាមលង្វែកមកដល់រជ្ជកាលព្រះអង្គឌួង

ក្រោយពីសម័យអង្គររុងរឿង ខាងសិល្បៈល្បីល្បាញក្នុងសាកលលោក ប្រទេសខ្មែរយើងបានជួបប្រទះនឹងសង្គ្រាមជាញឹកញាប់ ណាច្បាំងទល់នឹងប្រទេសជិតខាង ណាច្បាំងដណ្តើមបល្ល័ង្កគ្នាក្នុងស្រុក ។ នៅក្នុងរយៈសង្គ្រាមដូច្នេះប្រជាជនត្រូវគេបកៀសសឹកឬត្រូវគេណាធ្វើទាហាន ។ ប្រជាជនគ្មានសេរីសិទ្ធិ ។ វណ្ណៈខ្ញុំគេ អ្នកងារមាននៅក្នុងសង្គមខ្មែរយើង ។

ខាងសិល្បៈ ក៏មិនឃើញមានធ្វើអ្វីឲ្យធំដុំឡើយ ។ ម្នាក់ណាតែធំៗ នៅសម័យអង្គរបាក់រលាយទៅវិញ បានគប់

ក្តេចពោលក្នុងព្រៃជាចំណីក្តេជាតិ ។ ខាងសាសនាប្រជាជននៅកាន់ពុទ្ធសាសនា ។

ឯចំណែកអក្សរសាស្ត្រវិញ ក្រៅពីមានរឿងស្រង់ពីគម្ពីរពុទ្ធសាសនា យើងអាចឃើញមានស្ត្រាល្បែងច្បាប់ក្រម ក្តីកាល ដែលគេចងជាស្ត្រាស្លឹករឹត និងរឿងព្រេងនិយាយតៗគ្នា ។ រឿងទាំងអស់នោះមិនដែលដាក់ឈ្មោះអ្នកនិពន្ធ ហើយមិនដឹងជាសរសេររៀបរៀងនៅក្នុងពេលណាផង ។

មុននឹងពិនិត្យមើលអក្សរសាស្ត្រខ្មែរយើង សម័យនោះមានអត្ថរសដូចម្តេច ចង់ជាប៉ុន្មានចង្កោម យើងសូមពិនិត្យមើលការសិក្សានៅសម័យសក្តិភូមិនោះបន្តិច ។ ការសិក្សាសម័យនោះ បានមានសល់ស្លាកស្នាមនៅក្នុងសង្គមយើងសព្វថ្ងៃនេះ ដូចយើងអធិប្បាយខាងក្រោមនេះ ។

ក) របៀបសិក្សា — នៅសម័យនោះរបៀបសិក្សាធ្វើទៅតាមរបបសក្តិភូមិ។ កូនខ្មែរភេទប្រុសអាយុ៩ ឬ ១០ឆ្នាំ

បានចូលទៅនៅវត្ត ។ ក៏ទៅនៅបំរើលោកគ្រូ ដាំទឹក ដងទឹក ពុស ខុស តាមលោកទៅសូត្រមន្ត ទៅឆាន់ទៅទេសនា ។ល។

ការរៀនសូត្រគ្មានពេលម៉ោងហ្មត់ចត់ទេ ។ ក្មេងនៅជាមួយលោកគ្រូណាយកចិត្តទុកដាក់ក៏បានចេះមើលសរសេរខ្លះទៅ ។ ធម្មតាគេសង្កេតឃើញក្មេងចេះរៀនចាំមាត់ហូរ តែមើលអក្សរឬសរសេរផងមិនកើត ។

អាយុ១៥ឬ១៦ឆ្នាំ ក្មេងនោះក៏បានប្រែភេទចូលទៅបួសជាសាមណេរ បាន៤-៦ឆ្នាំក៏បានបំពេញជាភិក្ខុភាពឬ[illegible]សឹករៀបចំផ្ទះសម្បែងប្រពន្ធកូនវិញ ។

«បណ្ឌិត» តាំងនោះមានខ្លះមកប្រកបរកការធ្វើស្រែ ខ្លះទៀតក៏បានទៅផ្គាប់បុណ្យបានធ្វើស្មៀនមន្ត្រី។ល។ វិសេសគ្នាតរៀនក៏បានចេះជ្រៅជ្រះដែរ ដោយខ្លះបាន[illegible] [illegible]នៅប្រទេសសៀម ។

គ្រូអាចារ្យ សម័យនោះគឺលោកសង្ឃជាសាល[illegible] [illegible]ព្រោះលោកសង្ឃជាគ្រូបង្រៀន។ លោកសង្ឃជាអ្នក[illegible]

ជឿនលឿនជាងគេក្នុងដំបូន្មានស្របការ ។ លោកច្រើនផ្សាយធម៌ព្រះពុទ្ធឲ្យជឿឋានសួគ៌ និព្វាន «ឲ្យសុខចិត្តទទួលអត់ទ្រាំវេទនា ដោយជឿលើកម្មពីបុព្វ អន្ទោលតាមប្រាណមកគ្រប់ជាតិ» ។ ក្រៅពីនោះ លោកបានផ្សាយបង្រៀនជាដំបូង ច្បាប់ក្រម កេរ្តិ៍កាល ពាក្យចាស់ ស្ត្រាល្បែងជិនវង្ស លក្ខណវង្ស ។ល។ អាកប្បកិរិយារៀនសូត្រគឺច្រើនចូលចិត្តបង្ហាត់សិស្សឲ្យចេះ «ប្រើទុនលំពោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង កើតដោយប្រណិប័តន៍» ពោលគឺត្រូវរៀនឲ្យចេះលុតក្រាបដើរទាលួនប្រណម្យ លុតជង្គង់នៅចំពោះមុខលោកធំ ។

គ) កម្មវិធី–ក្នុងសម័យនោះច្រើនជួបប្រទះស្ទើរគ្រប់គ្នា នូវការរៀនសូត្រផ្សេង ១ ដូចតទៅនេះ :

១ - រៀនមន្តអាគមអូមអាមស្នេហ៍របៀបផ្សេង ១ ដែលជាការគ្មានសមហេតុសមផលចំពោះសម័យយើងសព្វ ៈ រៀនធ្វើគ្រូហ្មបុំពិសខ្ពុយ គ្រើអណ្ដាន ។ល។

២-រៀនធ្វើត្រូវតាមគាត់យល់សព្វ ៗ តែក្បួនហោរ នេះមិនបានគុតឆាប់ទេ ជាហេតុឲ្យមានពាក្យខ្មែរយើងបុរាណ ឆ្លើយប្រាប់ថា «ភូតនៅហោរ ចោរនៅជាង» ។

៣-រៀនគណិតស្តួចស្តើងណាស់ ៗ ចំនួនតិចណាស់ ដែលបានរៀនក្បាច់ចិន ហើយច្រើនទន្ទេញមេលេខជាភាសាចិន ៗ គេរៀនតែលេខបូកគុណ សងម៉ែត្រក្រឡ ៗ ជាការចប់ ៗ ចំណោទមិនសូវរៀនទេ ៗ

៤-ខាងអក្សរសាស្ត្រវិញគេរៀនច្បាប់ក្រម កេរ្តិ៍កាល កូនចៅ ស្ត្រីល្បែង សន្ធសិល្បជ័យ ជិនវង្ស ស្រាដុច គម្ពីរទេសនា មហោសថ សព្វសិទ្ធជាដើម; ៗ គេរៀនឲ្យមើលជាច់ដើរនិយាយប្រាប់គ្នាជាការចប់ ៗ តិចណាស់គេរៀនពិចារណាលើច្បាប់ទាំងនោះឲ្យយល់ ឃើញច្បាស់លាស់នូវហេតុនឹងផល ៗ

វិធីរៀនដែលផ្អែកទៅលើការទន្ទេញឡូ ៗ មិនសូវមាន

ការពិចារណាបានជម្រុញប្រជាជនយើងឲ្យជឿថា រឿងស្រ្តា ល្បែងជាការពិត ឲ្យជឿថាអ្នកកាន់អំណាចជាពោធិសត្វ ជាដំណាងព្រះពុទ្ធ ។

ការសិក្សាដែលជាអគ្គការសក្តិភូមិនេះ បានរាំងរាប្រជាជនយើងឲ្យនៅអណ្ដែតអណ្ដូង ជឿនូវការមិនសមហេតុសមផល ។ ការសិក្សាផ្អែកទៅលើជំនឿមិនមែនកើតមាននៅក្នុងសង្គមសក្តិភូមិខ្មែរម្នាក់ឯងទេឡើយ ។ វាបានកើតស្រដៀងគ្នានៅក្នុងសង្គមសក្តិភូមិក្នុងលោក ។ នៅក្នុងសង្គមសក្តិភូមិអឺរ៉ុប អ្នកកាន់អំណាចបានបង្ហិលប្រជាជនឲ្យជឿថា វាជាជាដំណាងព្រះម្ចាស់សួគ៌ ។ នៅសង្គមសក្តិភូមិអេត្យូប គេបានធ្វើឲ្យប្រជាជនយល់ថា «ហ្វ៊ាក់អ៊ុង» (ស្ដេច) ជាដំណាងទេវតាមហាម៉ាត់ ។ សង្គមសក្តិភូមិជប៉ុន គេបានបោកបញ្ឆោតប្រជាជនថា «មីកាដូ» ជាដំណាងព្រះអាទិត្យ ។

តែប្រវត្តិសាស្ត្របានធ្វើឲ្យយើងឃើញជាក់ស្ដែងថា វិធីបង្រៀនរបៀបសក្តិភូមិនេះ មិនបានទប់ទល់ប្រជាជនឲ្យនៅ

អណ្តែតអណ្តូងវង្វេងវង្វាន់ ៗ ការចំរើនទុំស្ងួតហ្មកម្មវិធីអក្សរសាស្ត្រ បានបណ្តុះជម្រុញប្រជាជនឲ្យមានគំនិតប្រាជ្ញាថ្មី ហើយឲ្យនំ
ស៊ើនតីរថយជាន់មុន ៗ

## អក្សរសាស្ត្របែកជាបង្គោមធំពីរ

តាមការពិនិត្យសង្គមខ្មែរយើង និងការសិក្សាព្រមទាំងការស្រាវជ្រាវសេរី ៗ នូវទំនៀមក្បួនខ្នាតដែលនៅសល់ទាំងប៉ុន្មានបានជាស្រាម្ចុនិយាយត ៗ ក្នុងកនោះ យើងអាចចងអក្សរសាស្ត្រខ្មែរយើងសម័យនោះ ជាពីរបង្គោមធំ ៗ ផ្ទុយប្រឆាំងគ្នានឹងការពាររំលើវណ្ណៈរៀងខ្លួន :

១)– អក្សរសាស្ត្រផ្សាយពីកវីចំណាន ៗ ដែលច្រើនទទួលការឧបត្ថម្ភពីក្រុមលង្វែកនឹងពុទ្ធ ៗ អក្សរសាស្ត្រដែលនេះបំរើវណ្ណៈខ្ពង់ខ្ពស់ និងការពារវណ្ណៈនោះ ៗ

២)– អក្សរសាស្ត្រប្រជាជន ជាអក្សរសាស្ត្របដិវត្តន៍

ផ្ទុយនឹងអក្សរសាស្ត្រផ្នែកទីមួយ ៗ អក្សរសាស្ត្រនេះ មិនបានចងក្រងជាស្ត្រាជាក់លាក់ទេ ហើយយើងច្រើនឲ្យឈ្មោះថារឿងព្រេង ៗ

X

X X

# ១- អក្សរសាស្ត្របដិកិរិយា

-អក្សរសាស្ត្របដិកិរិយា ផ្សាយចេញពីលទ្ធិព្រហ្ម និងពុទ្ធ ជាអក្សរសាស្ត្រកើតឡើងពីវណ្ណៈ ខ្ពង់ខ្ពស់ រៀបរៀង ហើយមានគោលបំណងធំការពារប្រយោជន៍វណ្ណៈខ្លួននោះឯង ៗ គេយកចិត្តទុកដាក់បង្ហាត់បង្រៀនប្រជាជនឲ្យចេះក្បួនច្បាប់ទាំងនោះណាស់ ៗ គេមានឲ្យចារចងក្រងជាស្ត្រាសឹករឹតដាក់នៅគប់វត្ត ៗ ហើយគេបង្រៀនឲ្យចេះដិតជាប់តាមក្បួននោះតៗគ្នាមក ៗ ក្នុងពពួកអក្សរសាស្ត្រផ្នែកនេះយើងអាចរាប់រឿងសាសនា ច្បាប់ក្រមប្រុស, ស្រី, កេរ្តិ៍ត្រ ច្បាប់កឹងកាំត្រ ស្ត្រាល្បើក, រឿងតាវ-ឯក ។ល។

ក) រឿងសាសនា– រឿងនេះច្រើនជារឿងដកស្រង់ពីគម្ពីរជាតក ដែលច្រើននិទានពីកំណើតព្រះពុទ្ធ កាលនៅជាពោធិសត្វនៅគ្រប់ជាតិ រឿងដែលព្រះសង្ឃយកទៅផ្សាយទេសនាឲ្យប្រជាជនជឿ មានរឿងសព្វសិទ្ធិ រឿងមហោសថ រឿងព្រះវេស្សន្តរ មេត្រីបា ក្រិស្នាបាដាលី រឿងកាកី រឿងពិម្ពា ពុទ្ធប្រវត្តិ ។ល។

ដើម្បីពន្យល់ប្រជាជនឲ្យជឿកំណើតនៃទុក្ខវេទនា ព្រះសង្ឃច្រើនទេសនាផ្អែកទៅលើ កម្មពីអតីតមនោរ្គាលតាមប្រាណ ហើយច្រើនយករឿងជាតកទាំងនោះជាឧទាហរណ៍ ។ ឯយើងសព្វថ្ងៃកឃើញទុក្ខវេទនាប្រជាជនគឺកើតមកពីការជិះជាន់របស់ចក្រពត្រ ពីការបោកបញ្ឆោតរបស់នាយទុនទៅវិញ ។

ខ) ច្បាប់ក្រមប្រុសស្រី–ច្បាប់នេះកូនខ្មែរដែលបានទៅរៀននៅវត្តត្រូវតែបានរៀនសូត្រគ្រប់គ្នា មានខ្លះចាំសូត្រ

បានមិនបាច់មើលស្ពានផង ។ ច្បាប់នេះជាក្បួនមួយ បំពាក់កិរិយាកូនខ្មែរតាំងពីកុមារទៅ ឲ្យចេះដាក់ឫកពាទន់ទន់ដើរ ៗ ស្របទៅតាមច្បាប់នៃវណ្ណៈខ្ពង់ពូកែក្នុងពេលនោះ ។

នៅក្នុងច្បាប់ក្រម គេបង្រៀនកូនខ្មែរឲ្យចេះលុតក្រាប «ប្រើទុនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង កើតដោយប្រណិប័តន៍» ច្បាប់ប្រុសបានប្រដៅកូនប្រុសឲ្យចេះផ្គាប់ផ្គុននឹងឲ្យប្ដូរជីវិតបំរើវណ្ណៈខ្ពង់ពូកែលុះអស់ជីវិត ។

ច្បាប់ស្រីបានតម្កើងប្រុស ហើយបង្គាប់ទៅស្រីឲ្យនៅគ្រប់លក្ខណ៍ជាទាសី ដោយកុំឲ្យហ៊ានឆ្លើយតបទៅនឹងប្ដី គន់តែប្ដីធ្វើខុសធ្ងន់លើដូចម្ដេចក៏ដោយ ។ ច្បាប់ស្រីដែលជាស្នាដៃបុរសកវី បានដាក់ស្រីឲ្យចុះញ៉មនឹងប្រុសយ៉ាងអស់ខ្នាត ។ នៅក្នុងសង្គមនេះ គេច្រើនមាក់ងាយស្រី ហើយគេប្រើនទុក «ស្រីដូចស្ពាន់ ប្រុសដូចពេជ្រ»

ច្បាប់ជំពូកនេះមានច្រើនណាស់ យើងមិនបាច់យកមករៀបរាប់ទាំងអស់ទេ ។ យើងគ្រាន់តែឲ្យដឹងថា ច្បាប់ទាំង

នោះគ្មានវិមំសាអ្វីក្រៅពីប្រដៅប្រជាជនឲ្យចេះលុតក្រាបនៅចំពោះមុខវណ្ណៈខ្លាំងពូកែនោះតែប៉ុណ្ណោះ ។

ក) ច្បាប់កិងកកេត្រ-- ដែលហៅថាច្បាប់កឹងកកេត្រ គឺរឿងរបៀបកាត់ក្តី ។ រឿងទាំងនេះច្រើនជាគំរូសម្រាប់តុលាការ ។ តាមសង្កេតមើលទៅប្រហែលជានៅសម័យនោះខ្មែរយើងមិនទាន់មានចងច្បាប់ព្រហ្មទណ្ឌ; ច្បាប់រដ្ឋប្បវេណីនៅឡើយ ព្រមទាំងមិនទាន់មានសាលាតុលាការជំនុំជំរះដូចយើងសព្វថ្ងៃនេះផង ។ ក្នុងរឿងកឹងកកេត្រគេច្រើននិទានពីគូក្តីទាស់គ្នា ប្តឹងទៅក្រមយោមរាជឲ្យកាត់ ។ មិនដាច់កាត់មិនរួច ក៏គេនាំរឿងនេះប្តឹងដល់ព្រះរាជា ។ ព្រះរាជាក៏កាត់សេចក្តីចុងបំផុត ។ ជាធម្មតាគេច្រើនលើកបង្ហាញថាការវិនិច្ឆ័យរបស់ព្រះរាជាទាំងប៉ុន្មានយុត្តិធម៌ទាំងអស់ ។ រឿងនេះមានគោលដំក្តាប់ប្រជាជនឲ្យយល់ឃើញថា ព្រះរាជាជាអ្នកទសពិធរាជធម៌ កាត់សេចក្តីត្រឹមត្រូវយុត្តិធម៌រឿងស្មុគ្រស្មាញទាំងប៉ុន្មាន

រឿងគឺងកំប្លែងមានច្រើនដូចជារឿងបុរសបាញ់ខ្ទង់ រឿងអាចារ្យរក្សាញញើព្រះរាជទ្រព្យ, រឿងចៅម្ចាស់ផ្ទះនឹងរឿងចៅសំបក ។ល។

ឃ) ស្រ្តាល្បែង — ដែលហៅថាស្រ្តាល្បែង គឺរឿងដែលច្រើនសរសេរជាពាក្យកាព្យ ហើយមានរឿងខ្លះដែងចង់ជាច្រើនវគ្គ ៗ រឿងទាំងនោះ ច្រើនយកទៅបង្ហាត់បង្រៀនកូនខ្មែរនៅវត្ត ៗ ល្ខោនបាសាក់, យីកេ, ល្ខោនបាសាក់ ក៏ច្រើនយករឿងអស់នោះមកលេងដែរ ៗ ដូច្នេះ រឿងស្រ្តាល្បែង បានជ្រាបចូលទៅក្នុងប្រជាជនទាំងស្រីទាំងប្រុស ៗ រឿងស្រ្តាល្បែងមានដំនើរ្យ គតនារីង្យ, ចិត្តសង្កា, ហង្សយន្ត សុទ្ធសិល្បជ័យ ។ល។ ស្រ្តាល្បែងច្រើនជារឿងដែលរៀបរាប់ស្រដៀងគ្នា ដូចតទៅនេះ ; ..មានកូនស្តេចមួយកើតមក កាលនោកុមារគេម្តាយចុង ឬ មាបណ្តេញចេញ ឬ យកទៅសម្លាប់ចោល ៗ តែធម្មតាមានទេវតា ក្នុងខ្លួនមកជួយនាំកុមារនោះទៅកន់ព្រៃ

ជួបការស្រមគាត់សី ឬ អ្នកចិត្តសប្បុរសផ្សេងទៀត យកទៅបង្រៀនមន្តអាគម «បេះដប់, ប្រក់ពល, បោះខ្លាំងពូកែ» ។ ដល់កម្លោះទៅជួបនឹងកូនស្រីយក្ខ ឬ កូនស្រីស្តេចជួបគ្នា ក៏ចាប់ចិត្តស្រឡាញ់ ។ ចាប់ពីពេលនោះក៏ដើរទៅជាមួយស្រីមានព្រាត់ប្រាស់គ្នា ដោយយក្ខឪពុកកូនស្រីពង្រាត់ ឬមួយទៀតដោយយក្ខិនីណាមួយមកលួងលោមឬក៏ស្រឡាញ់កូនស្រីគេក្រោយទៀត ។ ការព្រាត់ប្រាស់នេះច្រើនបណ្តាលឲ្យស្តេចដើរតាមឬដោះខ្លួន ក៏ត្រូវកើតមានសង្គ្រាមច្បាំងគ្នា ។ គេកេណ្ឌទ័ពមនុស្ស ទ័ពស្វា ឲ្យវាយនឹងទ័ពយក្ខ ដើម្បីដណ្តើមស្រីឬការពារស្តេចនោះ ។ ហើយធម្មតា កូនស្តេចដែលរៀនពីឥសីច្រើនឈ្នះជាដរាប ។ ដល់ចប់រឿង គេច្រើនប្រៀបប្រដូចថាស្តេចនោះជាពោធិសត្វ ហើយអគ្គមហេសីជានាងពិម្ពាដូចក្នុងរឿងជិនវង្ស គេប្រដូចថា ជិនវង្សបានយកកំណើតជាព្រះពុទ្ធ ហើយនាងចន្ទមសុរិយាជាតិក្រោយមកកើតជានាងពិម្ពា» ។

រឿងប្រៀបប្រដូចនេះបានបំពេប្រជាជន ដែលខ្វះក្ដីពិចារណាឲ្យជឿថា ព្រះពជាជាតំណាងព្រះពុទ្ធខ្ចប់សំណាចពីទេវស្ថានមក ហើយឲ្យប្រជាជនសុខចិត្តទទួលរស់នៅគោតក្រោមអំណាចសម្បូណ៌ជាសិទ្ធិរាជ ។

មួយវិញទៀតក្នុងរឿងស្ដាប់ល្បែងអ្នកកវីច្រើនផ្អែកទៅលើយល់សប្ដិ លើអំណាចឫទ្ធិនៃមន្តអាគមប្រកំពល, ពេះពោះ ជ្រកជ័ ដែលជារឿងកើតឡើងគ្មានសមហេតុសមផល ។

តែក្នុងពួកស្ដាប់ល្បែងទាំងនោះ យើងឃើញមានរឿងខ្លះ មានការចំឡែកឃ្លាតបន្តិចពីអាគមមន្ត ហើយផ្អែកមកលើស្នាដៃនៃវិទ្យាសាស្ត្រទៅវិញ ។

នៅក្នុងស្ដាប់ជ័នវង្សមានរឿងថា ‥ជ័នវង្សនឹងបទុមសុរិយា បាននាំគ្នាជិះហង្សយន្តហោះ ដល់កណ្ដាលសមុទ្រហង្សយន្តជាប់ខ្សែ អ្នកជិះទាំងពីរក៏បានធ្លាក់ចុះទៅក្នុងសមុទ្រព្រាត់ប្រាស់គ្នា ។ នៅក្នុង‥ស្ដាប់ហង្សយន្ត‥ក៏

មានរឿងមួយកន្លែងនិយាយពីជិះហង្សយន្តដូច្នេះដែរ ។

នៅក្នុងរឿង «នាងពីរដណ្តប់នាគ» យើងក៏បានឃើញរឿងនាងគង្គារី នាំខ្សែសនចូលក្នុងកដកំង ហើយពន្យល់ខ្សែសនអំពីក្អែកដែលគេខ្វះយកមកទុក ហើយទឹងថ្នាំដែលគេអាចយកទៅដាក់មើលក្អែកនោះ ប្រើការបានដូចមុនវិញ ។

ក្នុងរឿងខាងលើនេះយើងអាចសន្និដ្ឋានបានថា អ្នកកវីខ្មែរចំរើនខ្លះជំនាន់នោះ បានយល់ស្មានមករកវិទ្យាសាស្ត្រទៅអនាគត លះបង់ជឿមន្តអាគមដែលគ្មានសមហេតុសមផល ។ ចំពោះការស្មានដាក់ទៅរកវិទ្យាសាស្ត្រនេះ យើងអាចប្រៀបអ្នកកវីខ្មែរខ្លះជាន់នោះ ទៅនឹងអ្នកនិពន្ធបារាំងម្នាក់ឈ្មោះ ស៊ូល-វើន ដែលបានសរសេរសៀវភៅនៅសតវត្សទី ១៩ ស្មានជឿទៅខាងវិទ្យាសាស្ត្រ ។ ការស្មានរបស់អ្នកកវីជំនាន់នោះ ឥឡូវបានជួបនឹងការជាក់ស្តែងពិត

ប្រាកដ ដូចជាយើងមានយន្តហោះ នឹងថ្នាំសម្រាប់បន្តក់ភ្នែកខ្វះទៅហើយ ក្នុងសម័យយើងឥឡូវនេះ ៗ

ង) រឿងទុំទាវ ឯក— រឿងនេះជារឿងពិតជាក់ស្តែងមានក្នុងប្រទេសខ្មែរយើង នៅជំនាន់ប្រហែលសតវត្សទី១៥ៗ រឿងនេះបញ្ជាក់ឲ្យយើងឃើញរបបសក្តិភូមិ នៅប្រទេសយើងក្នុងពេលនោះ ៗ យើងសូមសរុបរឿងនេះសិន ៗ យើងសូមបញ្ជាក់ថា យើងសរុបតាមស្រ្តាស្លឹករឹតបុរាណ ។ នាយទុំកើតនៅបាភ្នំ ៗ ដល់អាយុគ្រប់រៀន ម្តាយយកទៅឲ្យនៅវត្តព្រះវិហារធំ ៗ ទុំនៅវត្តរៀនអាគមពូកែ ស្លូត ទេសនាសំឡេងបាន ៗ បួសជាសាមណេរ នេនទុំនឹងនេនពេជនៅវត្តជាមួយគ្នា ។ ពេលមួយក៏នាំគ្នាលាលោកគ្រូបររទេះទៅលក់តោកនៅស្រុកត្បូងឃ្មុំ ៗ ទៅដល់ភូមិជើងវាល (ស្លូងសព្វថ្ងៃ) នេនទុំនឹងនេនពេជ ឈប់សំរាក់នៅ ហើយនេនទុំដែលមានរូបសម្បត្តិ បានស្លូតទេសនាពិរោះល្បីល្បាញ បានក្តីរាប់អានពីអ្នកស្រុកទាំងស្រី ទាំងប្រុស ទាំ

ចាស់ទាំងក្មេង ។ នៅពេលនោះនាងទាវដែលជានារីល្បី ល្អក្រញខាងរូបសម្បត្តិដែរ ក៏បានដំណឹងពីនាងនោជាតិល្បៀង ថាមាននេនតូចកែស្ទិក នាងក៏ទៅស្ដាប់ធម៌ទេសនា សូត្រដែរៗ នាងទាវជាប់ចិត្តស្រឡាញ់នេនទុម បានបូជាផាហ៊ុំគ្រឡាប់ ប្រេងទឹកអប់ខ្លឹមចន្ទន៍ឈ្ងុយរំភើប ធ្វើឲ្យនេនទុមនៅជាសង្ឃ រកបានសុខចិត្តគ្មានផងលែងឃើញ ម្ល៉ោះហើយ នេនទុមតែង តែមានការនឹកទៅនាងទាវជានិច្ច ។ នាំនេនពេជត្រឡប់ទៅ វត្តវិញ ទុមបានបបួលគ្នាលាលោកគ្រូសឹកៗ លោកគ្រូបើកឲ្យ នេនពេជសឹកៗ ឯចំណែកនេនទុមមិនព្រមឲ្យសឹកទេ ព្រោះ „ទាយទោៈឃើញថាសឹកទៅមានអន្តរាយ ។ ទុមមានះទៅ ពឹងក្បោមស្រីឲ្យមកជួយអង្វរលោកគ្រូ ៗ នៅតែឃាត់ ។ តែ ទុមមិនយល់ព្រមផង ក៏បានទៅដោះស្បង់ចីពរនៅក្រោម ដើមឈើពាល់តែបាន ។

ក្រោយដែលនេនទុមត្រឡប់ទៅវត្តវិញ នាងទាវ ឧស្សាហ៍រំពឹងសេចក្ដីស្នេហារបស់នាងប្រាប់ទៅនោ ។ ចា

ព្រួយចិត្តដោយម្ដាយនាងឈ្មោះដួងដាន់ បានលើកនាងទៅ ឲ្យម៉ឺនងួនកូនអរជូនចៅហ្វាយស្រុកត្បូងឃ្មុំ ។

ទុមសឹករួចកាលណា ស្មូមស្មោលាទោសលោកគ្រូ សូមលាម្ដាយទៅត្បូងឃ្មុំជាមួយពេជ ។ ទុមបានរកឱកាស ទៅជួបទាវហើយបានរួមរក្សគ្នា ស្បថជាស្លាប់រស់ជាមួយគ្នាលុះ អស់មួយជីវិត ទាវមិនព្រមលុះតាមម្ដាយឲ្យខ្លួនទៅម៉ឺនងួនទេ ។

នៅសម័យនោះ ព្រះចៅខ្មែរព្រះនាមព្រះរាមា បានឮល្បីទុមពូកែច្រៀងហើយពេជពូកែខ្លុយ ក៏បានចាត់អាមាត្យ ឲ្យទៅកេណ្ឌយកមកលង្វែក ។ ទុមបានលានាងទាវ ហើយជាមួយពេជទៅបង្គំលាម្ដាយ រួចក៏ចុះទូកចូលគាល់ ស្ដេចក្រុងលង្វែក ។

ខ្លុយពេជនិងចម្រៀងទុម បានធ្វើឲ្យព្រះរាមាពេញ ចិត្តជាខ្លាំង ក៏បានលើកទុមជាម៉ឺនឯក ។ ក្រោយមកទៀត ព្រះរាមាបានចាត់នាម៉ឺនមន្ត្រី ឲ្យដើរមើលស្រីណាល្អ ដើម្បីយកមកធ្វើស្នំមហេសី ។ នាងទាវដែលមានរូប

សម្បត្តិក៏ត្រូវអាមាត្យចាប់យកមកលវង្វែក ឯម៉ឺនធ្ងន់នឹងអរជូន មិនហ៊ានទទឹងព្រះពជ៌រាជា ពិតមែនតែបានលើកស្លារួច ហើយ ។

យាយផាន់នាំនាងទាវមកលវង្វែក ។ នាងទាវមិនបានត្រេកអរនឹងមកធ្វើស្នំមហេសីទេ នាងនឹកទៅគូកំសត់ទុមជានិច្ច ឯចំណែកយាយផាន់កខិបកខុបត្រេកអរខ្លាំង លវង្វែក ដែលគាប់ប្រសើរនឹងនាងទាវ ។ ទៅដល់វាំងក៏ចូលគាល់ព្រះរាមា ។ ទុមឃើញនាងទាវដោយក្តីស្នេហាគូកំសត់ ក្តួចអំណាចព្រះរាមា ហើយក៏ច្រៀងទូលស្តេចថា ទាវជាគូសង្សារខ្ញុំ ។ ព្រះរាជាព្រួយទ្រោះ ខឹងនឹងទាវដោយហ៊ានស្រ-ឡាញ់ប្រុសចិត្តឯង តែមិនបានយកទោសផងទេ បែរជាសួរដណ្តឹងទៅទាវនឹងទុមឲ្យនិយាយប្រាប់ទៅវិញ ។ ទុមនឹងទាវឆ្លងស្របមូលមាត់គ្នាថាស្រឡាញ់គ្នាពិត ព្រះរាមាក៏បានរៀបការឲ្យជាប្តីប្រពន្ធហើយឲ្យទុមជាម៉ឺនឯក នៅគាល់ជាពជបំរើ ។

យាយផាន់ដែលជាចាស់ជរាមានបុណ្យសក្តិ ឃើញតាវបាន់មកទុំ កើតក្តៅក្រហាយ ក៏លាត្រឡប់មកភូមិដើមវាលវិញ ៗ មកដល់ផ្ទះគាត់និយាយជាមួយអរជូន ឲ្យដណ្តឹងតាវទៀត ហើយរកឧបាយកលពន្យាត់ការពីឯក ៗ ស្របគំនិតនឹងអរជូន យាយផាន់បានឲ្យគេទូលសុំទុំព្រមយក[illegible] តាវថា ខ្ញុំទិញឈើផ្ទះហើយសូមឲ្យតាវមកនាប់ ៗ តាវបានដំណឹងម្តាយឈឺ ក៏លាចៅមកជាមួយភិលៀងនោះ ៗ

ទៅដល់ដើមវាលឃើញម្តាយជា រៀបចំការនាងទំងម៉ឺនងួនទៅវិញ នាងតាវបានប្រកែកនឹងម្តាយតែម្តាយមិនស្តាប់ តាវបានសរសេរសំបុត្រទៅទុំឲ្យឆាប់ប្រញាប់មក ៗ ទុំដឹងរឿងក៏បានទូលលាព្រះរាជា ហើយនាំពេជមកជាមួយផង ទុំទៅដល់ផ្ទះដើមវាល ឃើញគេកំពុងរៀបការ ទុំបានស្និទ្ធស្នាលជាអស្ចារ្យជាមួយតាវនៅមុខគេ ៗ ឃើញដូច្នេះយាយផាន់អរជូនខឹងប្រើឲ្យចាប់ទុំយកទៅសម្លាប់ ៗ

តាវដឹងថាទុំត្រូវគេសម្លាប់ហើយ ក៏បានឲ្យនារកកាំ-

បិតស្លាហើយក៏នាំនាងនោះ គេចរត់ទៅផ្នូរខ្មោចទុម ។ ជួប ក្មេងឃ្វាលគោ ទាវដោះបិញ្ចៀនឲ្យក្មេង ពឹងឲ្យទៅប្រៀន នៅផ្ទះរៀបការថា៖ « អស់លោកតាស់ខ្ញុំស្លាប់ខ្ញុំណា លោកការនរណា ទាវទៅក្បៀយ មួយមួយនឹងគ្នាជាបីប្រាណ ស្លាប់ក្នុងស្មសានតាំងពីថ្ងៃ ដែលលោកយកទុមទៅប្រល័យ ស្លាប់តែហោងហើយក្រោមដើមពោធិ» ។

ដល់ផ្នូរទុម ទាវស្រាយផាហ៊ុំទុមហើយយកព្រះសង្ហាដាក់ លើខ្មោចទុម ។ នាងក៏បានចាក់កដេកស្លាប់ជិតទុមទៅ ឯនោក៏បានសម្លាប់ខ្លួនទៅជាមួយដែរ ។

ឯចំណែកក្មេងឃ្វាលគោក៏បានមកប្រៀងប្រាប់អ្នកការ ៗ ឆោឡោស្ដីដេរគ្នា ។ ចំណែកពេជវិញឃើញគេសម្លាប់ទុម ហើយទាវនឹងនោពៅសម្លាប់ខ្លួនដូច្នេះ ក៏រត់ទៅទូលព្រះកមា នៅលង្វែកវិញ ។ ព្រះកមាទ្រង់ក្រោធក៏បានលើកទាហានមក ត្បូងឃ្មុំ ហើយបានកាប់សម្លាប់អរជូនជូនដាច់ ព្រមទាំង ដាក់ប្រជាជនទៅស្រុកនោះថា «ឈ្នួកងារ» ។

រឿងនេះមានប្រយោជន៍សំខាន់ណាស់ អាចឲ្យយើងឆ្លុះមើលរបបគ្រប់គ្រងនៅជំនាន់នោះ និងគំនិតអ្នកស្រុក ។ យាយដាច់ជាម្ដាយ ប្រើអំណាចស្រឡាញ់បុណ្យ ហើយទុកដាក់កូនទៅបង្ខំចិត្ត ដូចជាមានពាក្យថា «ខ្ញុំមិនដែលធំជាងនាឡិ» ។ ទំនៀមទម្លាប់នេះ បានធ្វើឲ្យស្រីខ្លះ ទទួលយកប្រុស (ប្ដី) ដែលខ្លួនមិនស្រឡាញ់ ហើយខ្លះទៀតក៏ទទឹងមិនព្រមយកបានតែប្ដូរសម្លាប់ខ្លួនក៏សឹងមាន ។ រឿងនាងទាវនេះជាភស្ដុតាងស្រាប់ ។

ទុំនឹងទាវស្រឡាញ់គ្នាជាសុខ កុំតែមានយាយដាច់នឹងគេជូនទៅព្រ័ាត់ ។

ពេជជាកល្យាណមិត្ត ដែលយើងគួរយកតាំងបាន ។

អាកប្បកិរិយាអរជូន សឲ្យឃើញថា នាម៉ឺនមន្ត្រីជំនាន់នោះ មានគំនិតឃោរឃៅមានអំណាចដូចស្ដេចត្រាញ់ចាប់កាប់ប្រជាជនមានព្រ័ាត់ទាវនឹងទុំជាដើម ។

ស្ត្រីទាវឯកនេះ បានបង្ហាញឲ្យយើងឃើញជាក់ជា

អំណាចលើផ្នែកស្រាវជ្រាវរកស្រីមកថ្វាយជាដើម ៗ ស្តេចយាងទៅណា ដូចជាទៅត្បូងឃ្មុំត្រូវមាននាម៉ឺនស្រីស្នំច្រៀងសកកាទំហែតាមជានិច្ច ៗ ទៅដល់កំពង់ត្បូងឃ្មុំទៀត ក៏មានកេណ្ឌប្រជាជនឲ្យត្រាយផ្លូវទៅដើរខាល ៗ របៀបកាត់ក្តីទៀត ក៏គ្មានច្បាប់ឯណាជាធំក្រៅពីការវិនិច្ឆ័យផ្ទាល់របស់ព្រះកមា ដូចជាមានកាត់ទោសគ្រួសារអោយជូនហើយនឹងទម្លាក់ប្រជាជនឲ្យទៅជាអ្នកងារជាដើម ៗ

## រឿង ទាវ-ឯក របស់លោក វិបុលសេដា នូ-កន

ក្នុងការប្រឡងអក្សរសាស្ត្រ តាមព្រះរាជប្រកាស ១៩៤២ លោកនូ-កន ជាកវីអក្សរសាស្ត្រខ្មែរយើង បានយករឿង ទាវ-ឯកមកលើកជាថ្មី ៗ សៀវភៅទាវ-ឯក របស់លោកនូ-កន បានជាប់លេខបានរង្វាន់ ៗ តាំងពីនោះ

មកសៀវភៅ ទាវ-ឯក នោះ បានបោះផ្សាយលក់ឲ្យប្រជាជន មើលជាច្រើនលើក ៗ សៀវភៅនេះមានចំនួនប្រាំខ្សែ ៗ សាស្ត្រាចារ្យខ្លះនៅវិទ្យាល័យ បានយកសៀវភៅ ទាវ-ឯក លោក នូ-កន ទៅបង្ហាត់បង្រៀនសិស្ស ៗ តាមសង្កេតមើលទៅប្រហែលគេនិយមទុករឿង ទាវ-ឯក លោក នូ-កន ជារឿងពិតថាជាអក្សរសាស្ត្រទុកណា បានជាគេយកសៀវភៅនេះទៅបង្រៀន ៗ

ទាវ-ឯករបស់លោក នូ-កន ខុសឆ្ងាយពីរឿងដែលបានចងចារក្នុងសាស្ត្រាស្លឹករឹត ហើយដែលយើងបានបង្រួមរឿងខាងលើរួចហើយ ៗ ដោយផ្ទៃរឿងបាត់ច្រើនដូច្នេះ យើងខ្ញុំបានសួរបញ្ជាក់ថា: ហេតុអ្វីបានជារឿង ទាវ-ឯក ឃ្លាតឆ្ងាយពីសាស្ត្រាស្លឹករឹត, លោក នូ-កន បានឲ្យយោបល់ក្នុងការម្ភកថាថា:

«ដែលខ្ញុំតាំងរឿងនេះយកមកតែង គឺខ្ញុំយកតាមសំដី

អ្នកចម្រៀងក្នុងវាំង កាលរាជព្រះករុណានរោត្តមគង់ព្រះជន្មនៅឡើយ ម្ចាន់ច្រៀងថ្វាយព្រះសណ្ដាប់ ខ្ញុំស្ដាប់ចាំ ម្ចាន់ ឃើញថា សេចក្ដីចម្រៀងមានបញ្ហាល្អិតល្អ ៗ

ហេតុនេះខ្ញុំសូមឲ្យលោកអ្នកអានរឿងទាំងឡាយ កុំចូលចិត្តតែរឿងណាដែលពិតប្រាកដទើបចូលចិត្តអាន បើរឿងណាមិនពិតមិនចូលចិត្តស្ដាប់ មិនចង់អាន, មិនចង់ឮគេទៅ, សេចក្ដីដែលគិតដូច្នេះ នាំឲ្យមនុស្សយើងរឹតតែល្ងង់ខ្លៅទៅទៀត លោកអ្នកអានទាំងឡាយគិតមើលចុះ ! ៗ រឿងប្រលោមលោកខាងប្រទេសអឺរ៉ុប មានឈ្មោះឡាហ្វុងតែនថា: ដើមស្វាយនិងដើមបបុស ឬ សត្វរ៉ៃ នឹងស្រមោចចេះនិយាយគ្នា ៗ រឿងខាងប្រទេសអាស៊ីមានឈ្មោះធ្មេញជ័យអ្នកប្រាជ្ញ ខឹធិកាជ័យមេរគជាដើម បុរាណលោកតែងទុកជាប្រស្នា ឲ្យមនុស្សឆ្លាតចេះដឹងរឿងទាំងនោះ ថាជារឿងពិតដែរឬទេ ?

ខ្ញុំសុំពន្យល់បន្តិចទៅទៀត សូម្បីតែគម្ពីរក្នុងព្រះពុទ្ធ-សាសនាក៏មានអ្នកប្រាជ្ញតែងរៀងជាបាលីសុទ្ធដូចគ្នា ដូចយ៉ាងគម្ពីរមង្គលត្ថទីបនី មាននិយាយពីម្រឹគបក្សាវៈនិយាយគ្នា គម្ពីរសារត្ថសង្គហៈ មាននិយាយពីកំពស់ទំហំព្រះអាទិត្យ ព្រះចន្ទនឹងផ្កាយជាដើម គម្ពីរមហាវង្សមាននិយាយពីព្រះពុទ្ធ-ជាម្ចាស់ទ្រង់ធ្វើបាដិហារិយ៍បណ្ដេញយក្ខយកកោះលង្កា តើអស់លោកអ្នកយល់ឃើញថា គម្ពីរទាំងអស់នេះ ត្រឹមត្រូវណាស់ទៅឬ ? យើងអ្នកអានគិតត្រង់មែន នឹងមិនមែននោះទេ គឺត្រូវគិតដល់បញ្ហាសមហេតុសមផល បានជាប្រ-យោជន៍ឬមិនជាប្រយោជន៍តែប៉ុណ្ណោះ» ។

ការម្កកថាខាងលើនេះ បានបំភ្លឺយើងឲ្យដឹងថា គម្ពីរព្រះពុទ្ធសាសនាទាំងប៉ុន្មាន ច្រើនអ្នកប្រាជ្ញលើកជាប្រស្នាដូច្នេះ យើងអ្នកអានត្រូវគិតបញ្ហាមានសមហេតុសមផលបានជាប្រយោជន៍ឬមិនជាប្រយោជន៍ប៉ុណ្ណោះ តែមិនត្រូវជឿ

ដោយឥតការឆាំហរណា ឥតសង្ស័យ ។ ត្រង់ចំណុចនេះ យើងស្របគ្នាទាំងលោកទូ-កន តែយើងសូមជូនយោបល់បន្ថែមអំពីចម្រៀង ។ ចម្រៀងក្នុងវាំងក៏ដូចជាចម្រៀងរឿងជាធម្មតា អ្នកច្រៀងខ្មែរយើងច្រើនតែច្រៀងបំផ្លើសពីរឿងដើម ដោយមានចេតនាលើកតម្រូវអ្នកស្ដាប់តែប៉ុណ្ណោះ ។ អ្នកដែលបានស្ដាប់ចម្រៀងនោះក៏ច្រើនតែយកមកច្រៀងបំផ្លើសត ៗ មកទៀត ជួនកាលក្លាយខុសឆ្ងាយពីរឿងដើមហួសពេកក៏សឹងមាន ។ ដូច្នេះ យើងមិនអាចថាចម្រៀងមានបញ្ហាល្អិតល្អពិតជាងរឿងដើមឡើយ ។ អ្នកចម្រៀងយើង មិនចេះតាមពាក្យពេចន៍សេចក្ដីអ្នកនិពន្ធប៉ុណ្ណោះទេ គេច្រើនប្រើវោហារកាព្យឃ្លោងរបស់គេ ហើយបង្ខំក្រឡៃសេចក្ដីអ្នកនិពន្ធទៅវិញ ។

ម្យ៉ាងទៀត រឿងតាវ-ឯកជារឿងពិត មិនមែនដូចរឿងគាព្រោលៃល្បែងឬច្បាប់ក្រម ច្បាប់ប្រុសស្រី ។ល។ ដែលអ្នកតាក់តែងឡើង ដើម្បីយកមកដឹកពត់ចិត្តប្រជាជន ។ ដូច្នេះអ្នក

និពន្ធរឿងពិតជាក់ស្ដែង ត្រូវគោរពការពិត ហើយត្រូវទម្លាក់គំនិតផ្ទាល់ខ្លួនចោលឲ្យអស់ ។ ដើម្បីសរសេររឿងតាវឯកកុំឲ្យឃ្លាតឆ្ងាយពីរឿងជាក់ស្ដែង យើងត្រូវដាក់ខ្លួនទៅសតវត្សទី ១៤ ហើយស្រាវជ្រាវ រកឯកសារមើល ការរស់នៅនិងគំនិតសង្គមខ្មែរយើងក្នុងជំនាន់នោះ ព្រមទាំងឲ្យដឹងអាកប្បកិរិយា ទុមនឹងតាវឲ្យជាក់លាក់ផង ។ តាមសេចក្ដីនេះយើងឃើញថាតឹងណាស់ដែរ ព្រោះយើងគ្មានឯកសារប្រវត្តិសាស្ត្រឲ្យជាក់លាក់ផង ។

ក្រោយដែលបានមើលរឿងតាវឯក ទាំងពីររឿងសាស្ត្រាស៊ីការីតនឹងរឿងរៀបរៀងដោយលោកនូ-កន ខ្ញុំយល់ឃើញថាសាស្ត្រាស៊ីការីតនិយាយដាច់រឿងសម ហើយគួរណាស់តែយើងយករឿងនោះជាគោល សម្រាប់យើងចុះមើលសង្គមខ្មែរយើងនៅសម័យបុរាណ ។

ឯចំណែករឿងតាវឯកនៃលោកនូ-កន បានបញ្ចាំងយោបល់ផ្ទាល់របស់លោក នូ-កន នេះឯង ។ ក្នុងចម្រៀង

ដែលខុបព្រៀងថ្វាយព្រះកថា យើងមិនសង្ស័យថា ខុមហារិន ប្រយោព្រះមហាក្សត្រជួបេះទេ នៅសតវត្សទី១៩ ។ ចម្រៀងនេះទៀត គឺវែងហួសហេតុពិតអស់ខ្សែ ៣ ។

ចំពោះរឿងនេះ គួរណាស់តែសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៅវិទ្យាល័យ អនុវិទ្យាល័យ ឬ នៅសាលាបាលីជាន់ខ្ពស់ ឬវគ្គ ពិនិត្យរឿងនេះឲ្យមែនទែន ព្រោះរឿង ទាវ-ឯក ត្រូវយកទៅបង្រៀនជាដាច់ខាតក្នុងថ្នាក់ទី ៤ ឬ ៥ ទំនើបៗ

បើតាមយោបល់យើងៗ សូមឲ្យរៀនតាមសាស្ត្រាស្លឹករឹតវិញបានសមជាង ឬ ក៏ត្រូវតែចម្លងរឿងពីសាស្ត្រាស្លឹករឹតបោះផ្សាយចែកសិស្សនឹងគ្រូដែលត្រូវរៀនឲ្យមានគ្រប់គ្រាន់ឡើងៗ

## ២- អក្សរសាស្ត្រប្រជាជន

អក្សរសាស្ត្រប្រជាជន គឺរឿងព្រេងដែលប្រជាជនបាននិយាយតៗគ្នា រៀងរហូតមកពីមាត់មួយទៅមាត់មួយ ។ រឿងព្រេងច្រើនជារឿងខ្លីៗ ។ មានតែរឿងធ្មេញជ័យ; អាល្ងង់ដែលវែងបន្តិច ។ រឿងព្រេងជារឿងជឿនលឿន

សម្រាប់ជាសប្រជាជនឲ្យភ្ញាក់រលឹក ៗ ហេតុនេះហើយ បានជាវណ្ណៈខ្លាំងពូកែសម័យនោះ មិនបានយកចិត្តទុកដាក់ ចងជាសាស្ត្រាស្លឹករឹត ទុកឲ្យប្រជាជនរៀនទឹងពិចារណាគ្រប់ គ្នាឡើយ ៗ ផ្ទុយទៅវិញ គេច្រើនលើករឿងផ្តេសផ្តាស បំទុំ ដូចជាអាដ៏យមោរគ ហើយឲ្យយោបល់ថា រឿងព្រេង ទាំងនោះមិនសមរម្យថោកទាបសម្រាប់តែ „អាមនុស្ស ថោកទាប មានពូជអម្បូរទុគ៌ត" សម្រាប់តែវង់អាយ៉ៃ យកទៅឡកកំផុកកំផ្លែងលេង ៗ មានខ្លះទៀតថា រឿង ទាំងនេះជារឿងផ្គួគ្មានបានការអ្វីទេ ៗ បើពិនិត្យសេរ ១ យើងអាចជឿទៅតាមយោបល់ខាងលើនេះទាំងអស់ ៗ

រឿងព្រេងជារឿងប្រជាជន មានអត្ថរសខ្លឹមសារ ជំទាស់ពេញទីទឹងការអប់រំអយុត្តិធម៌ នៃសង្គមខ្មែរនៅសម័យនោះ ៗ ក្នុងរឿងព្រេងទាំងនោះ គេបានលើកអ្នកតួឯកឬ អ្នកគំរូតែជនសាមញ្ញកូនប្រជាជនពិតៗ គេមិនបានអណ្តែត អណ្តូងទៅប្រឌុបប្រឌែងរើសកូនទេវតាចុះពីឋានលើ ដូចក្នុង

សាស្ត្រាល្បែងឡើយ ។ រឿងព្រេងច្រើននិយាយពីការទាក់ទងមនុស្សពិតៗក្នុងសង្គមខ្មែរនិងសង្គមជាតិដទៃ មានជាតិចិន,ជ្វា,ជាដើម ដែលមករកស៊ីធ្វើសំពៅ ជំនួញនៅស្រុកខ្មែរយើង ។

## ក)- រឿងព្រេងបានប្រឆាំងពេញទី នឹងជំនឿការបន់ស្រន់ហាមានអ្នកតា

នៅក្នុងរឿង «អាទោរចិត្តជា» មានមន្ត្រីតូចម្នាក់ចង់បានឡើងធ្វើចៅហ្វាយស្រុក ព្រួយចិត្តដោយគ្មានលុយយកទៅថ្វាយស្ដេចទិញបុណ្យនោះ ។ នៅពេលយប់មួយមន្ត្រីនេះបាននិយាយប្រាប់ប្រពន្ធឲ្យជួយគិតរកប្រាក់ទៅទិញឋានន្តរស័ក្តិចៅហ្វាយស្រុក ។ ប្រពន្ធក៏បានឆ្លើយថា «យើងតុបតួបបន់ព្រះសុំឲ្យបានលុយ» ។ អាទោរចិត្តជាដែលយប់នោះទៅលបល្បួចមន្ត្រីនោះ ឃើញមន្ត្រីតុបតួបបន់ព្រះសុំលុយដូច្នោះ ក៏ករុណាតយកប្រាក់មកជូនឲ្យក្នុងយប់នោះទៅ ។ ព្រឹកឡើងមន្ត្រីក៏បានប្រាក់យកទៅទិញ[illegible]

ទៀនសក្ដិជាចៅហ្វាយស្រុក ។ល។

ក្នុងរឿង «មាយាស្រី(១), មានស្រីម្នាក់មិនស្រឡាញ់ប្ដីខ្លួន ព្រោះបានស្រឡាញ់ប្រុសផ្សេងទៀត ។ មានថ្ងៃមួយស្រីនោះដើរចូលព្រៃបន់អ្នកតា ៖ ជួនជាពេលនោះប្ដីនាងទៅរកដំឡូងនៅព្រៃនោះដែរ បានឃើញប្រពន្ធដើរទៅបៀត ក៏លបពួនក្រោយថ្មអ្នកតា ហើយចាំពិនិត្យមើលប្រពន្ធ ។ ប្រពន្ធនោះបានទៅបន់អ្នកតាសូមឲ្យកាច់កប្ដីឲ្យស្លាប់ទៅ ។ បុរសជាប្ដីពួននៅក្រោយដុំថ្មអ្នកតា ធ្វើជា «អ្នកតា» បានឆ្លើយតបមកវិញប្រាប់ឲ្យស្ត្រីនោះស្ងោរទានឲ្យប្ដីពេលល្ងាច ហើយប្ដីនោះមុខជាពុកពោះស្លាប់មិនខាន ។ល។

រឿងពីរខាងលើនេះ ដែលយើងបានដកស្រង់នេះជាកសិណពន្យល់យើងជាតុថា រឿងព្រេងខ្មែរមានគតិ ខ្លួនយើងដោយឧទាហរណ៍រស់រវើក ក៏ឲ្យយល់ភ្លាតគតិលោកនៅរឿងនឿអ្នកតាជួយឲ្យសោះ ។

(១) មើលសៀវភៅ អត្ថាធិប្បាយរឿងព្រេងខ្មែរ

១) រឿងព្រេងប្រឆាំងនឹងជំនឿមន្តអាគម- ក្នុងរឿង «សិស្សនិងគ្រូ» មាននិទានព្រះសង្ឃមួយព្រះអង្គធ្វើជាមេវត្តផង ។ ព្រះសង្ឃនេះត្រូវកូនសិស្សបោក លែងឲ្យរាវរកអំបិល ឲ្យឆាន់បាយក្រោយវាវិញ ។ ព្រះសង្ឃនោះខ្វល់ ក៏វាយកូនសិស្សៗបបួលគ្នាគេចរត់អស់ ។ ឃើញកូនសិស្សទៅអស់ លោកគ្រូក៏តាំងរៀនមន្តអាគម ។ ក្មេងឃើញដូច្នេះក៏បបួលគ្នាត្រឡប់មកវត្តវិញ ។ វាបញ្ឆោតលោកថា: «លោកគ្រូចេះមន្តអាគមពូកែ» ។ លោកគ្រូនោតស្មានថាក្មេងត្រូវមន្តអាគមរបស់ខ្លួនបានត្រឡប់មកវិញ ក៏រឹតតែជឿនូវមន្តអាគមថែមទៀត ។ ក្មេងវាបញ្ឆោតថា លោកគ្រូពូកែ ចេះបំបាំងគ្មាននរណាមើលឃើញ ។ ថ្ងៃមួយឧបាសកនិមន្តលោកទៅឆាន់ក្មេងបានប្រាប់កុំឲ្យលោកគ្រូស្លៀកស្បង់ គ្រង់តែចីពរបានហើយ ព្រោះលោកគ្រូចេះបំបាំងហើយ ។ លោកគ្រូក៏ធ្វើតាម ។ លុះទៅដល់ផ្ទះឧបាសក ពេលឆាន់លោកគ្រូវាយភ្លែនក៏បញ្ចេញកេរ្តិ៍ខ្មាសកណ្តាលវាល ឧបាសកកេះគ្នាសើច

លាន់ៗ លោកគ្រូរៀនខ្លាសំលាប់លែងបាន ។

រឿងនេះហើយទើបនៅមានរឿងច្រើនទៀត បានពន្យល់ប្រជាជនថាកុំឲ្យជឿមន្តអាគមបំពុកឲ្យសោះ ។

## គ)រឿងព្រេងប្រឆាំងនឹងរបបសង្គមផ្តាប់ឪពុកក្មេក–

យើងបានដឹងគ្រប់គ្នាថា ពិតមែនតែគេ «ទុកស្រីដូចស្លាទ ប្រុសដូចពេជ្រ» ឪពុកម្តាយខាងស្រីមានអំណាចសម្បើមណាស់ៗ គាត់មិនគ្រាន់តែបង្ខំកូនស្រីគាត់ឲ្យយកប្រុសដែលគាត់មិនស្គាល់ទេ គាត់មានឥទ្ធិពលសំឡុតកូនប្រសាប្រុសមកផ្តាប់គាត់ឲ្យធ្វើតាមបំណងរបស់គាត់ទាំងអស់ ។ ចំពោះរឿងនេះ មានរឿង «ឪពុករើសកូនប្រសា» បានបង្ហាញគំនិតពុតអាក្រក់នៃឪពុកម្តាយក្មេក ។ ឪពុកកូនស្រីបានដាក់កំរិតឲ្យកូនប្រុសត្រាំធ្វើការ ដែលគាត់មានខ្មៅយកឈើប្រើទាំងប៉ុន្មាន ដូចជាមានគូរកុំឈប់សុំបាយ បើកាលណាខ្ញុំមិនស្រេក ប្រើកូនប្រសាឲ្យធ្វើឆ្នៃទៅរកអណ្តើក ។ល។ កូនប្រសាឆ្លាតលបស៊ើបកលល្បិចដឹងមុន ក៏បានធ្វើយតបតាម

យោះយៅ បង្អត់ប្ដាយពុកក្មេកវិញ បណ្ដោយពុកក្មេកទៅ កែអណ្ដើក ធ្វើឲ្យពុកក្មេកធ្លាក់ពីលើស្ពាន ។ល។ ទាល់គំ-និតក៏សុខចិត្តឲ្យកូនស្រី ។

រឿងនេះប្រឆាំងពេញទី នឹងរបបពុកម្ដាយក្មេកធ្វើបាប កូនប្រុសទៅផ្គាប់ខ្លួន មានឲ្យគ្នាលុតលួនក្រាប តែមុខរបេះ គោខ្ទះផង ។ល។

ដើម្បីឲ្យដឹងច្បាស់ស្រួលស្ដាប់រឿងព្រេង សូមអ្នកអាន មើលរឿងទាំងនោះ ។ យើងស្ដាយជាខ្លាំង ដោយយើងមិន អាចបង្រួមគ្រប់រឿងបានព្រោះក្នុងអត្ថបទ អក្សរសាស្ត្រ ខ្មែរនេះ យើងគ្រាន់តែរកញែកមើលគំនិតអក្សរសាស្ត្រ តែប៉ុណ្ណោះ ។

៥) រឿងអាឡេវ- «កាឡេវ» ជារឿងព្រេងដែលប្រជា ជនបានដឹងស្ទើរគ្រប់គ្នា ។ ពួកក្រុមការ៉ៃបានយករឿងនេះ ច្រៀងលេង ហើយមានទាំងថតដាក់ថាសម៉ាស៊ីនច្រៀង ផង ។ កាឡេវជាកូនប្រជាជនម្នាក់ ។ មួយជីវិត គឺប្រ

ទាំងនឹងទំនៀមទម្លាប់សង្គមក្នុងសម័យវា ។

ធម្មតាគេទូន្មានកូនស្រីតែទុកទំនៀមទម្លាប់ចាស់ទុំជាត្រឹមត្រូវ តែអាខ្យៅមិនបានស្របតាមពាក្យទូន្មាននោះទេ ។ វាបានបង្ហាត់ឆ្កែវាឲ្យហាត់រត់ ៗ បន្ទាប់មកចង់ស៊ីទំ អាខ្យៅបានរៀបចំផ្សំផ្គុំផ្ទះម៉ែវាទៅវិញ ។ ចំណែកព្រះសង្ឃដែលមានទំនៀមជឿ ច្រើនគម្ពីរជាអ្នកប្រាជ្ញបណ្ឌិតសុចរិតយុត្តិធម៌ត្រឹមត្រូវគិតតែសម្បត្តិ «ស្ងួនទិញខ» អាខ្យៅបានលើកគូព្រះសង្ឃគង់នៅវត្តមួយ ឲ្យយើងឃើញផ្ទុយទៅវិញ ។ ព្រះសង្ឃមួយអង្គនោះបានពឹងអាខ្យៅរកស្រីកញ្ញាឲ្យទៅវិញ ។ តែអាខ្យៅធ្លាក់វៃបាននាំសង្ឃអង្គនោះទៅដល់ទីអាចក ។ ខ្មាចវៃបកការយ៉ោយមានទោសបារាជិក ព្រះសង្ឃអង្គនោះក៏មានភ័យស្លុតប្រញាប់ដែលបានពាក្យគ្រលំប៉ាងនៃទុក្ខសោក ទុក្ខសិកា ឲ្យទោសអាខ្យៅដល់ម្ភៃបាត្រ ។

ជាមួយសង្គមចោរ អាខ្យៅ ដើរនូវលើឈ្មោះចោរបាន យកសំពៅ ៥០០ ពីចោរ ។

ទៅកាន់ទីក្រុងនៅបំរើសេដ្ឋី អាឡេវបានត្រូវសេដ្ឋីលើក កូនស្រីឲ្យធ្វើជាប្រពន្ធ ។ អាឡេវនៅតែមានចារិតប្រជាជន ដដែលមិនបានរោះដោយធនធានទេ ។ វាទៅជួបអស់នាម៉ឺន មន្ត្រីនៅព្រះពន្លាមុខវាំង កាន់ចារិតប្រជាជនធម្មតា ។លុះ ឃើញកូនស្រីសេដ្ឋី ដែលត្រូវជាប្រពន្ធវាដើរទៅ វាក៏និយាយ ថាវាអាចប្រើកូនស្រីសេដ្ឋីឲ្យយកហិបស្លាម្លូជូនវា ។ នាម៉ឺន មាក់ណាយវាមិនជឿក៏បន្តុះបង្អាប់វា ។ អាឡេវបានបបួល ភ្នាល់ នាម៉ឺនយល់ព្រម ។ លុះដល់កូនស្រីទៅដល់ក៏ យកម្លូស្លាបារីឲ្យវាមែន ។ អាឡេវភ្នាល់ឈ្នះនាម៉ឺនទាំងអស់ បានទ្រព្យជាច្រើន ។

នាទីអាឡេវមានតែក្នុងសង្គមគ្រួសារ, វត្តលោកសង្ឃ, ចោរ,សេដ្ឋី,នាម៉ឺនតែប៉ុណ្ណោះ ។ យើងបានសង្កេតឃើញថា គង់តែនាម៉ឺនមានអំណាចអាងយ៉ាងពស្ត្រ ក្នុងសម័យនោះដូច មានអា-ជូនក្នុងរឿងចៅ-ឯកជាដើម ក៏អាឡេវកូនប្រជាជន មិនព្រមចុះចាញ់ហើយបានជ័យជំនះទៅវិញ ។

ច) រឿងធនញ្ជ័យ – រឿងព្រេងនេះល្បីសុះសាយ ។ ប្រជាជនបានដឹងស្ទើរគ្រប់គ្នា ហើយច្រើនដកស្រង់ចំពូកខ្លះយកទៅនិយាយកំសាន្ត ។ តែដូចរឿងព្រេងផងទាំងពួង រឿងធនញ្ជ័យមិនបានបោះពុម្ពផ្សាយឲ្យប្រជាជនមើលគ្រប់គ្នាទេ ។ សិស្សខ្មែរនៅវិទ្យាល័យ មិនអាចរកសៀវភៅរឿងព្រេងអក្សរសាស្ត្រខ្មែរមើលរៀនគ្រប់គ្នាឡើយ ។

រឿងធនញ្ជ័យមានអត្ថរសខ្លឹមសារល្អណាស់ ។ រឿងព្រេងនេះជាស្នាដៃប្រជាជនខ្មែរយើង នៅសម័យសក្តិភូមិ ។ យើងសូមដកស្រង់ចំពូកខ្លះ ហើយនិយាយកាត់ ១ ដូចតទៅនេះ ៖

...ធនញ្ជ័យជាកូនអ្នកស្រែ ។ ពុំខ្លាចទៅលេងផ្ទះមហាសេដ្ឋី ។ ថ្ងៃមួយពុំមានអាយុប្រហែល ៧ ឆ្នាំ ប្រពន្ធសេដ្ឋីស្តីពីរើសគ្រួសឲ្យ ហើយសន្យាថាឲ្យអំបុកពាំ ។ ធនញ្ជ័យបានរើសគ្រួសរួចបានទារអំបុក ។ ប្រពន្ធសេដ្ឋីឲ្យអំបុក តែធនញ្ជ័យនៅក្រាញយំថាតិចណាស់ ។

សេដ្ឋីមកឃាន់ស្លរដើររៀនហេតុក៏បែកអំបុកជាពីរគំនរ ហើយប្រើឲ្យធ្មេញជ័យរើសគំនរអំបុកណាច្រើនយកទៅចុះ ៗ ទឹងទឹងទាញ់ពោកសេដ្ឋី ធ្មេញជ័យបានឲ្យម្ដាយគាត់ យកទៅលក់ធ្វើជាខ្ញុំមហាសេដ្ឋី។ ធ្មេញជ័យបានទុកសេដ្ឋីជាអ្នកពូកែតែយកចំណេញមួយធំជាសត្រូវរបស់គាត់ ដូច្នេះក្នុងកំឡុងគាត់ធ្វើខ្ញុំសេដ្ឋី គាត់បានធ្វើល្បិចកលបំផ្លាញកិត្តិនាមឲ្យអប្បយសទីងរលាយផងគានទៀត ដូចមានរឿងរើសគាថមសេះដាក់ថង់យាម, ចាំចំការឲ្យគោស៊ីដំណាំអស់ៗលៗ សេដ្ឋីពាល់ដំរីក៏បានយកធ្មេញជ័យទៅថ្វាយស្ដេច ។

បានខ្ញាស់ថ្មី ធ្មេញជ័យមិនដើរខ្សែក្រោមទេ គាត់លេងល្បែងលើជានិច្ច ។ • គាត់ករយ៉ាងស្រស់ថ្វាយស្ដេច អំពីក្បួនករ ។ ស្ដេចបានត្រិះរិះគ្រប់គល់ល្បិច ដល់មាន់,ដល់ក្របី, ទៅក្រសាលព្រៃដំរីសេះ, មុចទឹកថ្វាយពាំងមាន់ស្ដេច ៗលៗ ដើម្បីយកទោសធ្មេញជ័យតែធ្មេញជ័យដោះស្រាយឈ្នះរួចខ្លួនជានិច្ច ។ ក្នុងដំណាក់ជាទីលំនៅ អស់

នាងស្រីស្ងំ ធ្មេញជ័យត្រូវស្ដេចប្រើទៅបោសប្រាស ។ គាត់បានទីងទីងអស់នាងដើរលើក្បាល ក៏ជេរថា : «មេបោរ រកស៊ីតែខឹងក្ដិត» ។ អស់នាងប្ដឹងឲ្យចាប់ទោសធ្មេញជ័យ ។ បានឆ្លើយថាជេរពីងពាងក្នុងសំបុកវិញទេ ។ នៅពេលស្ដេចប្រើស្រីស្ងំឲ្យទៅជុះដាក់ផ្ទះធ្មេញជ័យ ៗ ដេញវាយ ។ ត្រូវជាប់ទោសទៀត តែធ្មេញជ័យបានឆ្លើយថា: «បានជាវាយព្រោះស្រីទាំងនោះនោម» ។ ព្រោជាធ្មេញជ័យបានធ្វើឲ្យស្ដេចមានបារម្ភជាច្រើន ម្ល៉ោះហើយក៏ប្រើឧបាយឲ្យធ្មេញជ័យទៅខេត្តក្រៅ ៗ តមកធ្មេញជ័យត្រូវជាប់ទោស ស្ដេចឲ្យយកទៅសម្លាប់ ។

នៅលើទូកពេជ្ឈឃាតនាំទៅសម្លាប់ ធ្មេញជ័យបានដើរនយោបាយបង្កើតចម្រៀង «ធ្មេញជ័យធ្លាក់ទឹក ! ហៃអើៗ» ។ លុះធ្មេញជ័យលោតមុជទឹកគេចទៅ ។ អ្នកចែវទូកមួយក្រុមស្រែកថា: «ធ្មេញជ័យធ្លាក់ទឹក» ពួកមួយក្រុមទៀតស្រែកបន្ទរឡើងថា: «ហៃអើៗ» ។

ក្រោយមកធ្មេញជ័យបានទៅបួសជាភិក្ខុ ។ បន្ទាប់មកធ្មេញជ័យ បានដោះប្រស្នាឈ្នះអ្នកប្រាជ្ញចិនល្បីល្បាញ ។ ធ្មេញជ័យ បានត្រូវទៅស្រុកចិន ។ ស្ដេចក្រុងចិនបានចាប់គាត់ដាក់គុក ។ ដើម្បីឲ្យរួចពីគុកធ្មេញជ័យ បានធ្វើឯកបន្ទើរខ្ទង់ បន្ទីស្លូរសព្ទធ្វើឲ្យស្ដេចចិនដេកមិនលក់ ជាមូលហេតុនាំឲ្យធ្មេញជ័យមកស្រុកខ្មែរវិញ ។

នៅពេលឈឺខ្លាំងជិតស្លាប់ ស្ដេចទៅសួរធ្មេញជ័យ ។ បានខ្សឹបផ្ដាំថា៖ «ស៊ីត្រីព្រួលកុំចោលស្រកា បើស៊ីត្រីប្រាកុំចោលស្រកី ឲ្យស៊ូត្រីប្រាទីងមួរសណ្ដាន់ » ។ លុះស្ដេចត្រឡប់ទៅវាំងវិញ អស់នាម៉ឺនបានសួរស្ដេច តើធ្មេញជ័យបានផ្ដាំដូចម្ដេចខ្លះ ស្ដេចបានឆ្លើយប្រាប់តាមធ្មេញជ័យប្រាប់ទាំងអស់ ។ អស់នាម៉ឺនជឿជាក់ថ្កល់មិនគិតស្មានថា ធ្មេញជ័យជាអ្នកប្រាជ្ញនិយាយដូច្នោះ ក៏ច្រលនិយាយថា «យើងទុកចិត្តថាស្ដេចជា ៗមិនបានទេ បានជាស្រុកខ្មែរយើងខ្វាចស្ដេចលុកជន្ល់នំប៉ុច្នេះ» ។

មុននឹងស្លាប់ធ្មេញជ័យ បានផ្តាំឲ្យគេស្រះបន្ទាលើផ្នូរគាត់ ។

សៀវភៅធ្មេញជ័យ – សព្វថ្ងៃយើងរកសៀវភៅរឿងនេះណាស់ ។ គេឃើញមានចុះរឿងនេះក្នុងទស្សនាវដ្តីកម្ពុជ-សុរិយាជាពាក្យរាយដែរ តែចំនួនសៀវភៅតិចពេក ។

ម្យ៉ាងទៀត យើងឃើញលោក មាស-សាម បានមានគំនិតបោះពុម្ពរឿងធ្មេញជ័យខ្សែទី ១ ជាពាក្យកាព្យដែលជាស្នាដៃកវីបណ្ឌិតម្នាក់មិនស្គាល់ឈ្មោះ បានរៀបរៀងនៅ ព.ស ២៤៩៦ ។ យើងស្តាយជាខ្លាំងដោយមិនទាន់ឃើញខ្សែទី ២ តទៅទៀត ។ យើងសូមឲ្យលោក មាស-សាម បោះពុម្ពផ្សាយរឿងនេះឲ្យចប់ ដើម្បីឲ្យប្រជាជនយើងនឹងនិស្សិតខ្មែរបានក្រេបជញ្ជក់អត្ថរសអក្សរសាស្ត្រយើង ។

ង) រឿងសុភាទន្សាយ – រឿងនេះកើតឡើងតាមទៅរឿងកឹងកក់ទ្រ ហើយមិនខុសពីរឿងកឹងកក់ទ្រប៉ុន្មានឡើយ ។ រឿងសុភាទន្សាយជាគំរូកាត់ក្តីមួយដែរ ។ នៅ

ក្នុងរឿងព្រេងនេះគេយកសុភាទន្សាយជាចៅក្រមផុតលេខ ១ ឯចំណែកក្នុងគំនិតខ្មែរគេលើកមហាក្សត្រជាចៅក្រមជាន់ខ្ពស់ៗ រឿងសុភាទន្សាយខាងកាត់ក្តីមានច្រើន ដូចរឿងខ្លាទោល ជេកត្រូវពស់វែកចឹក ។ល។

ក្រៅពីរឿងកាត់ក្តីនេះ អ្នកនិពន្ធប្រជាជនខ្មែរយើងបុរាណបានលើករឿងផ្សេង ១ ទៀតនិយាយត្រដាងអំពីគំ-និតអាកប្បកិរិយារបិញរបុញ របុលរបូចរបស់អាសុភាទន្សាយចៅក្រមជាន់ខ្ពស់ ។

ក្នុងរឿង «កេ មាន់ អក ខ្លា នឹងទន្សាយប្រជុំគ្នាធ្វើផ្ទះ» គេឃើញទន្សាយពូកែច្រើនណាស់ ។ ដើម្បីឲ្យជនឃើញច្បាស់សុភាទន្សាយចៅក្រមផុតលេខ យើងសូមស្រង់រឿងនេះមកពិចារណាខ្លះ ។

កេ មាន់ អក ខ្លា នឹងទន្សាយប្រាំនាក់ បានស្របយោ-បល់គ្នាធ្វើផ្ទះនាំគ្នាទៅរកប្រូតស្បូវ ។ ដល់ពេលស្បូវគេក៏ធ្វើជែ (ពេង)៖គេបាត់ឲ្យខ្លាចាំជែ ។ កេ មាន់ អក ទន្សាយទៅប្រូត

ស្បៀវ ៗ គេ, មាន់, អក បានប្រឹងប្រែងស្រូវគ្មានហ៊ានឈប់ ឯចំណែកអាពៅក្រុមទន្សាយខ្លួន ធ្វើពុតជាឈឺ ហើយគេចដើរលេងទៅលបមើលខ្លាវិញ ៗ ក៏ទៅលបមើលឃើញខ្លាចាប់ក្តាន់ រួចលួចអាសុភាទន្សាយ បានត្រឡប់មកកន្លែងប្រែស្បៀវធ្វើជាគ្រុនញ័របមួលគេ, មាន់, អក ទាយអ្នកលួច តើខ្លាគេអ្វីបានស៊ីៗ ក៏ស្គាល់ថាមានក្តាន់ស៊ី ហើយបើកាលណាក៏ទាយត្រូវ គេ មាន់ អក មិនត្រូវស៊ីទេ បើក៏ទាយខុសវិញគឺក៏មិនត្រូវស៊ីដែរ ៗ លួចទៅជញ្ជៅដៃ ក៏ធ្វើជាសួរខ្លាហើយឃើញបានក្តាន់ស៊ីមែន ក៏ហួនហែងមិនឲ្យគេ មាន់ អកស៊ី តែគេ មាន់ អក ដេរបន្ទោសស៊ីទាល់តែបាន ៗ

ថ្ងៃបន្ទាប់មកវេនទី២ ទី៣ ទី៤, ត្រូវវេនគេ អក មាន់ចាំដៃម្តងម្នាក់ ១. ៗ ម្នាក់ៗបានកំប៉ះនឹងទទួលវេនខ្លួនគេម្ហូបស៊ីគ្រប់គ្រាន់ ៗ ឯចំណែកអាសុភាទន្សាយវិញ ទៅប្រែកស្បៀវនៅតែប្រើគំនិតបោកស៊ីខ្លាំងគេជានិច្ច ក៏គេចធ្វើជាឈឺពោះ

ដើរលបមើលអ្នកចាំដៃទៅវិញ ហើយបបួលគាយម្ហូបជូត
មុនទៀត ៗ

ថ្ងៃទីប្រាំត្រូវវេនអាស៊ុកាទន្សាយចាំដៃ ៗ ដោយវាមិន
ដែលប្រកបការកេស៊ីនឹងខ្លួនវាម្ដងឡើយ អាស៊ុកាទន្សាយ
គាលគិតជាភ្នាំងនឹងកម្ហូបឲ្យខ្លា ភេ មាន់ អក ទៅច្រូតស្រូវ
ស៊ីល្អាច ៗ ម៉្លោះហើយវាដែលគ្មានការពិសោធន៍ក្នុងការធ្វើ
ពលកម្មផ្ទិចសោះក៏ធ្វើការមិនសម្រេចឡើយ ដំបូងវាត្រាប់
ខ្លាទៅរកចាប់ក្ដាន់ តែក្ដាន់មានមាឌធំបានវែកវាដួលផ្ដាប់មុខប្រ
ឡាក់គក់ពក្លក់អាក្រក់មើល ៗ បន្ទាប់មកវាត្រាប់កេទៅមុជ
ចាប់ត្រីបានរូសវាជ្រមុជទឹក វាភ័យខ្លាចក្សួយបានលែងត្រី
ចោលបេះឡើងមុខក្រញោន ត្រចៀកក៏ប្រោនដូចស្លា មុខមាត់
ស្លុញប្រឡញណាស់ញ័រជើងដៃ ៗ តមកទៀតអាស៊ុកា
ទន្សាយត្រាប់អក ៗ វាឡើងចុងឈើលោតចាប់ត្រីត្រូវត្រីនាំ
ជ្រមុជទឹកទៀត ទន្សាយភ័យស្ទើបឡើង ៗ ...ត្រូកវាស្លុត

មើលមុខតាត្រកក់ស្លាប់តាំងសម្បុរសស្លាំង ហាក់ដូចមុខខ្មោចព្រាយ ”ៗ

ចុងបំផុតតាត្រាប់មាន់ ៗ ក៏យកឆ្នាំងមកចំអិតផុះហើយ ក៏ស្វារគន្ទះឆ្នាំងទុកឲ្យ កេ មាន់ អក ខ្លា អ្នកធ្វើការនឿយហាត់ស៊ី ឯចំណែកតាវិញតាធ្វើពុតជាឈឺដេកទទូរ ៗ ក៏ស៊ីមិនបានទេ ក៏ទុកឲ្យកេ មាន់ អក ខ្លា ស៊ី ៗ ដល់សត្វទាំងបួនស៊ីឆ្អែតក៏មិនចាល់ពុតទេ ៗ ក៏ក្រោកស្រែកថាគេស៊ីតាចម៌ក៏ ៗ សត្វទាំងបួនខំដេញតាទន្សាយ ក៏រត់បាត់ទៅៗ ដល់ល្ងាចសត្វទាំងបួនត្រឡប់មកវិញ ដោយខឹងនឹងតាសុតាទន្សាយ ១ ក៏ត្រឡប់មកវិញបបួលគ្នាដឹកស្រូវយកទៅផ្ទះ ៗ

គេស្រុះគ្នាផ្ទុកស្រូវលើខ្នងខ្លា ៗ ទន្សាយក៏ដិះបរខ្លាហើយដុតស្រូវនោះឆេះពេញលើខ្នងខ្លា ១ រត់ត្រវីត្រពាត ៗ ទន្សាយលោតរត់ទៅឡើងដើមសង្ស័រ ៗ ខ្លាតាមទៅទាន់ប៉ងនឹងចាប់ទន្សាយខាំស៊ីឲ្យក្ស័យ ៗ លើកនេះទន្សាយដោះតាមកលល្បិច ចុះពោះឈើលែងបានទៀតហើយ ព្រោះ

គេបានស្គាល់ពុតវាអស់ ៗ ដូច្នេះវាក៏អួតបញ្ឆោតប្រាប់ខ្លាថា ទេវតា ព្រះឥន្ទ ទេព្រ័ក្សបានប្រើវាមកបួតស្អឹកសន្ស័រ ហើយបើខ្លាហ៊ានស៊ីវា ខ្លាឯងមុខជាត្រូវចុះនរកយ៉ាំងជ្រៅ ៗ ខ្លាខ្លាចនរកដែលសុភាទន្សាយគាបន្លឺត ក៏សំប្រថស្បែមមិនព្រមហ៊ានស៊ីទន្សាយ ហើយសូមបួតស្អឹកសន្ស័រលេងជាមួយផង ៗ តមកទៀតអាសុភាទន្សាយនៅក្រមថុតលេខ បានទៅនៅយោលទោងលើវល្លិ៍ ទៅអង្គុយលើឫស្សីស្រម្លៀតគ្នា ទៅអង្គុយនៅបៀតសំបុកឪម៉ាល់ ដោះសារប្រាប់ខ្លាកុំឲ្យទំរឹងខ្លួនថា សុទ្ធតែទេពតាព្រះឥន្ទប្រើខ្លួនឲ្យមកលេងភ្លេង ៗ កលល្បិចនេះបានធ្វើឲ្យខ្លាធោតល្ងង់ជឿរឿងទេវតា ព្រះឥន្ទ ទេព្រ័ក្ស ត្រូវដាច់ទោងដួល ត្រូវបង្ក្រាបករុយត្រូវឪម៉ាល់ទិច ៗ ទីបំផុតទន្សាយត្រូវខ្លា[illegible] ក៏តក់ភ័យទៅធ្លាក់អណ្ដូង តែវាចេះកលល្បិចបានបញ្ឆោតបំភ័យថាមេឃរលំលើ ៗ ខ្លាភ័យក៏តេបួលទៅក្នុងអណ្ដូង ៗ បន្ទាប់មកខ្លាទំរឹងទំទន្សាយ ក៏បោះទន្សាយចេញ

មកក្រៅអណ្តូង ហើយទន្សាយរួចពីអណ្តូងក៏ស្រែកឲ្យអ្នកស្រុកសម្លាប់ខ្លាហោង ៗ

សុភាទន្សាយចៅក្រមផុតលេខ បានប្រើគ្រប់កលល្បិចបោកប្រាស់អ្នកមានកម្លាំងកាយដែលគ្មានថ្ងៃ ៗ ចង់ស៊ីចេក «ទន្សាយធ្វើពុតជាស្លាប់ស្អុយ» ដើម្បីឲ្យយាយទូលចេកបែកញើសរើសកដាក់ក្នុងកញ្ជើ ៗ ជាប់អន្ទាក់ទន្សាយក៏យំណាស់ខ្លាចមនុស្សស៊ីក៏អង្វរគីង្គក់ឲ្យជួយដោះខ្លួន សន្យាថានឹងមើលស្រែងឲ្យជា ៗ រួចពីគ្រោះថ្នាក់កាលណាទន្សាយចំអកឲ្យគីង្គក់ថា ស្រែងពីដីដូនដីតាមកគ្នានេះណាមើលជាទេ ៗលា

ក្នុងរឿង «តេ មាន់ អក ខ្លា ទន្សាយ» នេះ យើងបានសង្កេតឃើញថា ភាសុភាទន្សាយ «ចៅក្រមផុតលេខ» គ្មានធ្វើការអ្វីទេ គិតតែដើរបោក ហើយការ កួតយកទៅគា ទេត្រក្យ ព្រះឥន្ទមកបោកខ្លា ដែលជាអ្នកមានកម្លាំងពីរដូការច្រើនជាងគេ ៗ សូមបងប្អូនអ្នកអានពិចារណារឿងនេះទៀតមើលទៅ ៕

## អក្សរសាស្ត្រខ្មែរក្នុងនឹមអាណា-និគមនិយមបារាំង ទល់ឆ្នាំ១៩៤៥

នៅសតវត្សទី១៨នៅប្រទេសអឺរ៉ុបវិទ្យាសាស្ត្រនិងតិកនិក បានចំរើន ឧស្សាហកម្មគ្រួសារបាត់រលាយ ហើយទុក កន្លែងឲ្យឧស្សាហកម្មរោងចក្រធំ ៗ ដែលប្រើកម្មករគូលីរាប់ ពាន់នាក់ ៗ ការបង្កើនផលបានលឿនលឿន ជាបុព្វហេតុមួយ ធំ ជម្រុញឲ្យប្រទេសអឺរ៉ុបនាយទុនដើររុកទន្ទ្រានរកប្រទេសចំ ណុះ ដើម្បីធ្វើជាផ្សារសម្រាប់លក់ទំនិញវា ហើយនឹងទិញទំ និញវត្ថុដើមត្រឡប់ទៅវិញ ៗ ដូច្នេះហើយបានជាប្រទេសនាយ ទុនបារាំង អង់គ្លេស ហូឡង់ដែល បានមកដណ្តើមគ្នាជិះជាន់

បណ្តាប្រទេសនៅអាស៊ីមាន ឥណ្ឌា ឥណ្ឌូណេស៊ី ម៉ាឡាយូ ឥណ្ឌូចិន ហ្វីលីពីនជាដើម ។

នៅប្រទេសឥណ្ឌូចិនខ្មែរ លាវ វៀតណាម ត្រូវអាណានិគមនិយមបារាំងដាក់ជាចំណុះរបស់វា ។ វិធីដម្បូងគឺវាប្រើលោកសង្ឃកាតូលិកឲ្យមកប្រចុបប្រចែង ប្រដៅសាសនាយេស៊ូគ្រិស្ត ។ បន្ទាប់មកវាក៏យកកាំភ្លើងនឹងកប៉ាល់បង្ខំស្រុកខ្មែរយើងឲ្យដាក់ខ្លួនជាចំណុះវា ។ តែការជិះជាន់របស់អាណានិគមនិយម បានជួបប្រទះការតស៊ូដ៏អង់អាចរបស់ប្រជាជនខ្មែរយើង ។ លោកអាចារ្យស្វា, ពោកំបោរ, ស៊ីវត្ថា, ហែម-ចៀវ, បានសរសេរប្រវត្តិសាស្ត្រតស៊ូទុកជាកេរ្តិ៍តំណែលឲ្យយើងគ្រប់គ្នា ។ ព្យាករណ៍ទាំងនោះ ពួកអាណានិគមនិយមបារាំងបានក្លែងដាក់ជាអ្នក «ក្បត់ជាតិ» ទៅវិញ ។

ក្រោយដែលដាក់ប្រទេសយើងជាចំណុះអាណានិគមនិយមបារាំងបានប្រើគ្រប់កលល្បិច បំផ្លាញបំបាត់ប្រជាជាតិខ្មែរយើងពីផែនទីសាកលលោក ។

ខាងនយោបាយក៏ផ្អែកលើរបបសក្តិភូមិ ហើយបាន
បង្កើតភ្នាក់ងារនាម៉ឺនឲ្យបន្តដែកទៅប្រហារប្រជាជនយើង ។
ខាងសេដ្ឋកិច្ច ក៏បង្កើតពន្ធមួយរយចំពូក ជាន់កប្រជាជនយើង
ហើយក៏ចាប់ដីវាញ់ ៗ ធ្វើជាចំការកៅស៊ូនិងបញ្ជូនវត្ថុដើមនិង
ទ្រព្យសម្បត្តិទៅប្រទេសគេ ។ សរុបទៅជាង៨០ឆ្នាំក្រោម
នឹមដែកអាណានិគមនិយម, ប្រជាជនយើងត្រូវគេខ្ទប់មាត់
បិទភ្នែក ចុកត្រចៀកគ្មានស្គាល់សេរីភាពសិទ្ធិបន្តិចឡើយ ។

ទោសទុក្រិដ្ឋរបស់អាណានិគមនិយម មិនមែនអស់ត្រឹម
ដូចរាប់រៀបខាងលើនេះទេ ។ ខាងវប្បធម៌ ក៏ប្រើគ្រប់វិធី
បំបាត់អក្សរសាស្ត្រយើង ។ ក៏មានគ្រោងការសិក្សាបង្វែរកូន
ខ្មែរឲ្យបេះខ្ចីមវប្បធម៌របស់ជាតិខ្លួន ។ កលល្បិចក៏មានច្រើន៖

១-បង្កើតសាលាបារាំង-ដើម្បីបង្ហាត់បង្រៀនកូន
ខ្មែរឲ្យធ្វើជើងឈ្នួល បន្តដៃពួកអាណានិគមបារាំង

ក៏សង់គុកច្រើនជាងសាលារៀន ។ ប្រជាជនជាងបួន
លាននាក់ មានវិទ្យាល័យតែមួយ ។ ឯចំណែកកន្លែងគុក

ត្រអាលកំសាន្តសម្រាកសម្រាប់ពួកវាមិនខ្វះទេ ដូចផ្ទះទៅកែប បូកគោ ចុងកាឡូ ។ល។ ចំពោះផ្ទះទាំងនោះប្រជាជនខ្មែរមានភារៈគ្រាន់តែទៅសង់ ទៅជួសជុល ទៅបោសលានជាការស្រេច ។

គោលបំណងសាលាបារាំង គឺខំកំផ្លួកូនខ្មែរ កុំឲ្យមានវិជ្ជាលើសពីឆ្លើយ «វី! ណុង! (បាទ! ទេ!)»។ វាបង្ខំកូនខ្មែរឲ្យរៀនភាសាបារាំង ៖ បណ្តុះយើងឲ្យមានសតិអារម្មណ៍យល់ថា ភាសាបារាំងថ្កើង ហើយទាញយើងគ្រប់គ្នាឲ្យខ្ពើមមាក់ងាយអក្សរជាតិយើង ។

ក្នុងកម្លុងជាង ៨០ ឆ្នាំ កូនខ្មែរដែលបានរៀនបារាំងឈប់ស្គាល់អារ្យធម៌ខ្មែរ, វប្បធម៌ខ្មែរ ហើយថែមទាំងអណ្តែតអណ្តូងទៅតាមឃោសនាវា ជឿថាខ្មែរគ្មានវប្បធម៌គ្មានអក្សរសាស្ត្រផង ។ អារ្យធម៌ដែលអាណានិគមនិយមយកមកបង្រៀនយើងគឺអារ្យធម៌អាណានិគមនិយម មិនមែនអារ្យធម៌ប្រជាជនបារាំងទេ ។

**នៅគ្រប់ផ្លូវការ** វាគាត់បោលអក្សរខ្មែរយើង ហើយ**វាយក** **ភាសាបារាំងមកប្រើជំនួស** ។ ខ្មែរបេះខ្មែរ គ្មានតម្លៃ **ខ្មែរណាចេះភាសាបារាំង**មួយម៉ាត់ពីរម៉ាត់ អាចបានធ្វើក្លូន **«ភោគជំ»** ។ គំនិតក្រខ្វក់លាមករបស់វា មានច្រើនទៀត **យើងមិនអាច**រៀបរាប់ទាំងអស់បានឡើយ ។

២– ក្តាប់បណ្ឌិតអក្សរសាស្ត្រខ្មែរ ដើម្បីលាក់អំពើ **លាមកវា** ដែលបដិសេធអក្សរសាស្ត្រខ្មែរពីគ្រប់ផ្លូវការ គ្រប់ **ក្រសួង** វាធ្វើបញ្ចើចបោកកូនខ្មែរថាវា បានថែរក្សាច្បាប់ខ្មែរ ដោយបង្កើតពុទ្ធសាសនបណ្ឌិត ហើយប្រមូលអ្នកប្រាជ្ញ ឲ្យមកធ្វើការបំរើវា ។ ដោយវិធីនេះ អាណានិគមនិយម បារាំង បានចូលទៅក្តាប់លោកសង្ឃឲ្យដើរស្របតាមនយោបាយវា ។ ការចាត់តាំងរើសមេគណៈមានរាជាគណៈ ជាដើម សុទ្ធតែត្រូវតែគ្រោះទទួលយល់ព្រមពី «លោកធំ» ទាំងអស់ ។ អ្នកស្រីការប៉ៃលែស ជាភ្នែកច្រមុះរបស់វា ដើម្បី ក្តាប់បញ្ញាបណ្ឌិតខ្មែរនៅក្រោមបង្គាប់គាត់ ឲ្យធ្វើការតម្រូវ

នយោបាយអាណានិគមនិយមៗ ដូច្នេះ អាណានិគមនិយម អាចមើលស្ទង់គំនិតអ្នកប្រាជ្ញខ្មែរខ្លះ តើមានគំនិតផ្ទុយនឹងរបបគេ ក៏នឹងស្រួលចាប់ចង ៗ ម្យ៉ាងទៀត ដោយវិធីនេះក៏បានឃាត់កូនខ្មែរកុំឱ្យទៅរៀនប្រទេសក្រៅ ។ល។

**៣- នៅក្នុងរបបអាណានិគមនិយមអក្សរសាស្ត្រខ្មែរសាបសូន្យ** ព្រោះការអាណានិគមនិយមបាំងគឺ បំបាត់ប្រជាជាតិខ្មែរៗ ធម្មតាតែប្រជាជាតិបាត់អក្សរសាស្ត្រមុខជាសាបសូន្យ ។ ដូច្នេះហើយបានជានៅក្នុងរវាងជាង ៨០ឆ្នាំ អ្នកប្រាជ្ញខ្មែរពិតប្រាកដមិនបានគង់វង្សមានច្រើន ហើយក៏មិនបានទុកស្នាដៃដូចពេលមុនឡើយ ។ ក្នុងនឹមចក្រពត្រអ្នកប្រាជ្ញប្រជាជនកើតមិនបានទេ ព្រោះគ្រាន់តែរៀបដុះពន្លក ត្រូវពួកចក្រពត្រអាណានិគមនិយមក្តិចចោលភ្លាមហើយបំផ្លាញពាក្យ ថាក្បត់ ថាចោរ ក៏សឹងមាន ។ អាចារ្យហែម-ចៀវ ជាភស្តុតាងស្រាប់ ។

បើយើងនិយាយដូច្នេះប្រហែលជាពួកអាណានិគមនិយម

ខ្លះ បានឆ្លើយតបមកវិញថា យើងនិយាយឲ្យរួចតែពីមាត់ ដោយឃើញអាណានិគមនិយមបារាំងដួលដេកក្រោម ហើយ គេមុខតែចង់ប្រាប់យើងថា អាណានិគមនិយមបានបើក ផ្សាយសៀវភៅកម្ពុជសុរិយា ហើយបានទាំងបើកច្បាប់ឲ្យ ផ្សាយអក្សរសាស្ត្រចំណាស់ ៗ «ដូចគតិលោក» របស់លោក សុគន្ធ ប្រើជាតន្ត្រ ជាដើម ៗ លោកតាក្រមង៉ុយ ដែលជាកវី ប្រជាជន ក៏ត្រូវបានអនុញ្ញាតផ្សាយច្បាប់ប្រុសគាត់ដែរ ។ យើងគ្មានជំទាស់នឹងយោបល់ខាងលើនេះទេ ។ យើងគ្រាន់តែ ជំរាបថា ចំនួនសៀវភៅផ្សាយមានស្តួចស្តើងណាស់ ហើយ សៀវភៅទាំងនោះ ក៏គ្រាន់តែជាវនាំងដឹកនាំប្រជាជនឲ្យសុខ ចិត្តនៅក្រោមរបបចក្រពត្រតែប៉ុណ្ណោះ ។ កម្ពុជសុរិយាច្រើន បានចុះសេចក្តីប្រែអត្ថបទរបស់អ្នកនិពន្ធបារាំងខ្លះ និងព្រឹត្ត ការណ៍ទទួលលោកធំបារាំងនោះជាការចប់ ៗ ក្រៅពីនេះ មានប្រែធម៌បាលីខ្លះ ដែលសុទ្ធតែបារាំងពិនិត្យមើល

មុន ៗ តទៅនេះយើងសូមពិនិត្យមើលសៀវភៅ «គតិលោក»

«គតិលោក» — ក្នុងរបបអាណានិគមនិយម អ្នកនិពន្ធគ្មានសេរីភាពសរសេរបោះផ្សាយតាមយល់ខ្លួនទេ ៗ ព្រោះសៀវភៅធម៌ក្តីត្រូវរាជការបាក់ពិនិត្យសិន លុះណាតែរាជការយល់ព្រមទើបបោះផ្សាយបាន ៗ ដូច្នេះហើយ សៀវភៅក្បួនខាងប៉ុន្មានត្រូវសរសេរដូចម្តេចគោរពសរសើរ ដល់របបអាណានិគមនិយម ហើយបើហ៊ានទាស់ទៀងវិញ ត្រូវគេធ្វើទោសរហូតជៀសមិនផុតឡើយ ៗ ក្នុងគតិលោកនេះ លោកកវីឥន្ទបានលបតែងរឿង «កូនចៀមនឹងចចក» បញ្ចាលកំហឹងទាស់ទៀងដល់របបផ្តាច់ការបូរាណសម័យនោះជាសេចក្តីថាៈ

«មួយទៀត បើនរណា ពួកណាប្រទូស្ត គិតក្បត់ផែនដីក្តី ប្តូវទឹងរឹងរូសគតិដាក់ព្រះមហាក្សត្រិយ៍ក្តី ច្បាប់ត្រូវប្រហារជីវិតទាំងត្រកូល ឯពួកញាតិពូជនោះ ត្រូវទម្លាក់ដាក់ជាពល ជាអ្នកងារ មានឲ្យត្រូវបោចសក់សេះសក់ដំរីជា...

គ្រាអស់កប្បអស់កល្បទៅ ៗ សត្វដែលកើតក្នុងវង្សនោះចុះឈ្មោះជាអ្នកងារជាលេខមួយទាំងអស់ ទោះប៉ុន្មានៗគ ក៏ពុំរួចផុតពីព្រងារទីងគេឡើយ ៗ សត្វណាដែលកើតក្នុងពូជនោះទោះជាបេះដូងការអ្វី ១ ឬមានប្រាជ្ញាយ៉ាងណាក្តី ក៏តាំងខ្លួនពុំបានហៅថាសត្វឥតកំពូកក្នុងលោកនោះឯង ៗ ច្បាប់ដែលជាមកនេះ ជាប់ជាទម្ងន់ទៅខាងអ្នកតាបប្រាកដ មួយទៀតច្បាប់នេះ បើមាននៅក្នុងប្រទេសណាហើយ អ្នកប្រាជ្ញណានឹងគិតគេចឲ្យរួចចេញទៅពុំបាន បើចង់រួចចេញនោះបានតែរត់ចោលស្រុកគៀសខ្លួនទៅប្រទេសដទៃទៀត នោះទើបបាន ដូចនិទានលោកគាសុខពន្ធ» ៗ

គតិលោកនិងច្បាប់គាន្ធីយក៏មិនអាចហាមបញ្ចេញគោលបំណងចិត្តនៀនលោកជំណា ដោយពេញមុខឡើយ ព្រោះច្បាប់ទាំង៤នោះគ្រូឲ្យបាក់ងគ្រូគគ្រាពិនិត្យ ព្រោះប្រជាជនគ្មានសេរីភាពនិងសិទ្ធិសរសេរនិយាយបោះពុម្ពផ្សាយ ៗ

ហេតុនេះយើងអាចយល់ថា «គតិលោក» ជាច្បាប់

ស្របពេញទីទៅតាមពាក្យខ្លួន 'អាណានិគមនិយមនិងសក្តិភូមិ ។ ចំពោះសៀវភៅគាត់នេះ លោកតាឥន្ទ បានផ្តើមសេចក្តីថា

«តម្រាគតិលោក គឺខ្ញុំបាទឧកញ៉ា សុត្តន្តប្រីជាឥន្ទអ្នកតែងឡើង ដើម្បីកុលបុត្រអ្នករៀនគតិបូរាណជាបែបយ៉ាងគ្រាន់តាមសេចក្តីប្រៀបនាំមកប្រាប់គតិលោកថ្មី ដែលកើតមានឡើងទើបតាំងជាបុច្ឆា (សួរ) និងពាក្យវិសជ្ជនា (ឆ្លើយ) ក្នុងតម្រានេះ ជាទីសណ្តាប់ដោយងាយ» ។

ក្នុងសេចក្តីផ្តើមនេះ យើងអាចសង្កេតឃើញពាក្យ «គតិបូរាណ» និង «គតិលោកថ្មី» ដែលមានន័យដូចខាងក្រោមនេះ ។

ពាក្យ «គតិលោកបូរាណ» មានន័យជាច្បាប់សក្តិភូមិ គឺមុនបារាំងអាណានិគមនិយមបារាំងចូលមកមាន «ច្បាប់ក្រម ត្រីនេតិ ច្បាប់ស្រី» ។

ពាក្យ «គតិលោកថ្មី» មានន័យជាច្បាប់លោកសម័យ

អាណានិគមនិយម (ចក្រពត្រ) លាយឡំនឹងសក្តិភូមិ ។

ដូចន័យខាងលើនេះ យើងឃើញថាសៀវភៅ «គតិលោក» ជាដំបូន្មានរបស់រាជការអាណានិគមនិយម ដែលផ្អែកទៅលើសក្តិភូមិ ។ បើដូច្នេះ យើងអាចថា «គតិលោក» មានផ្នែកខ្លះចាស់ហួសសម័យប្រទេសយើងសព្វថ្ងៃ ឯករាជ្យប្រជាធិបតេយ្យ សព្វថ្ងៃ ។ ហេតុនេះ យើងត្រូវបដិសេធចោលគតិណា ដែលចាស់ហួសមិនត្រូវ ។

តែបើយើងនិយាយខាងអក្សរសាស្ត្រវិញ យើងឃើញថាលោកគាធន្ធ ជាអ្នកនិពន្ធមួយចំណានក្នុងជំនាន់គាត់ ។ គតិលោករបស់គាត់ បានបញ្ជាំងឲ្យយើងឃើញការរស់នៅសង្គមជាច្រើន ។ លោកគាធន្ធបានជ្រើសរើសលើករឿងជាក់ស្តែងឲ្យយើងឃើញដូចរឿងឃុនកាត, ចៅសន, រឿងពាលហួសប្រមាណ ។ល។ ដែលគ្មានសៀវភៅណាមួយក្រៅពីនេះទុកឲ្យយើងដឹងឡើយ ។

ម្យ៉ាងទៀត លោកគាស្មូតនិពន្ធប្រើឆន្ទ ដែលជាអាចារ្យ

ព្រះពុទ្ធសាសនាមួយយ៉ាងឯក បានប្រដៅយើងកុំឲ្យជឿអ្នកតា យាយទេព ធ្វើសក្ការៈបូជាទឹកបឹងផ្តេសផ្តាស ។ ត្រង់ចំណុចនេះ លោកតាឥន្ទ បានអធិប្បាយយ៉ាងគ្រោះគ្រាយនៅក្នុងគតិលោកខ្មែរបី ត្រង់រឿងធ្វើសក្ការៈ បូជាទឹកបឹង, ដើមដង្កោ, គោស្នាវខ្មៅ, យាយទេព, រឿងភ្នំក្រោមនៅខេត្រសៀមរាប ទឹងភ្នំត្រនិលនៅក្នុងស្រុកជើងព្រៃ ។ល។

**ច្បាប់ក្រមង៉ុយ** – លោកតាង៉ុយ បានសរសេររឿងប្រដៅប្រជាជនបីបួនច្បាប់ដែរ ។ គាត់ជាកវីប្រជាជន ។ គាត់បានជួយឈឺឆ្អាល ដោយឃើញកសិករបាក់កំលាំងដាក់ពន្ធរស់ជាច្រើន ហើយដាស់តឿនប្រជាជនឲ្យខំធ្វើការ ។ គាត់ប្រដៅលោកសង្ឃកុំឲ្យពាស់គ្នាពីធម៌ថ្មីចាស់ ហើយទាំងសូមកុំឲ្យលោកសង្ឃសុំលុយចិនចាយ ។ តែដូចលោកតាឥន្ទ លោកតាង៉ុយ ក៏ស្របទៅតាមរបបសក្តិភូមិ អាណានិគមនិយមទាំងអស់ ។

## អក្សរសាស្ត្រខ្មែរក្រោយសង្គ្រាមលោកលើកទីពីរ

នៅឆ្នាំ១៩៤៥ ក្រោយដែលកងទ័ពសហភាពសូវៀត បានរំដោះមនុស្សជាតិពីក្រញាំហ្វាស៊ីស្ត អាល្លឺម៉ង់និងហ្វាស៊ីស្តជប៉ុន, អ៊ីតាលី, ប្រជាជននៅស្រុកចំណុះទាំងប៉ុន្មាន បានក្រោកឡើងតស៊ូដើម្បីយកឯករាជ្យ ប្រជាធិបតេយ្យ ។ ស្ថានការណ៍សាកលលោកនឹងការតស៊ូប្រជាជនខ្មែរគ្រប់ជាន់ថ្នាក់ បានបង្ខំចក្រពត្រូវបារាំងលាក្រញាំបន្តិច ៗ អាណានិគមនិយមបារាំង បានត្រូវបង្ខំបើកអំណាចឲ្យយើងមានសេរីភាពបន្តិចបន្តួច តែអំពើយង់ឃ្នងឃោរឃៅក៏មាននៅដដែល ។ ប្រជាជនខ្មែរបានបង្ហូរឈាមតស៊ូរៀងរហូតមក លុះដល់ជ័យជំនះហ្សឺណែវនៅថ្ងៃ២១ កក្កដា ១៩៥៤ ដែលសម្រេច

ប្រទេសយើងបានសន្តិភាព ឯករាជ ប្រជាធិបតេយ្យ ។

ក្នុងរយៈនេះ តើអក្សរសាស្ត្រខ្មែរយើង បានប្រែចំរើនដូចម្តេចខ្លះ ? យើងអាចសង្កេតឃើញពិតមែនតែត្រូវអាណានិគមនិយមចុកមាត់ ចាប់ចងអ្នកនិពន្ធរឿងផ្សេងៗជាច្រើនបានកើតចំនួនជាលំដាប់ ។ អ្នកនិពន្ធខ្មែរបានអត់ធ្មត់សរសេរប្រលោមលោក មានខ្លះបកប្រែចេញពីសៀវភៅភាសាជាតិដទៃ ។ ស្ទើរពេលត្រីមាស មានសៀវភៅថ្មីៗ ជាច្រើនក្បាលចេញផ្សាយលក់គ្រប់បណ្ណាគារក្រុង ខែត្រដែលខំត្រដរកើតឡើង ។

ប្រៀបនឹងស្តាល្បងសម័យមុន យើងឃើញប្រលោមលោកមានដំណើរចំរើនគ្រាន់បើ ព្រោះអ្នកនិពន្ធប្រលោមលោកយើង បានជ្រើសរើសតួឯកនៅលើដីមិនឲ្យ [illegible] អណ្តែតឡើងទៅរកតួ [illegible] ទេ ។ យើងឃើញរឿងប្រលោមលោកទាំងនោះ ច្រើននិយាយពី «ប្រុសស្រី» [illegible] សាត់ទៅជួបនឹងអ្នកមានធនធាន ឬ មានយស

សក្តិ មានចិត្តសទ្ធាជ្រះថ្លាជួយចិញ្ចឹម ។ ជួនកាលអ្នកមានជ្រះថ្លាបានយក «ប្រុសប្ញស្រី» កំសត់ធ្វើជាកូនប្រសា, កូនចិញ្ចឹមប្ញប្រពន្ធទៅក៏មាន ។ បន្ទាប់មកអ្នកកំសត់នោះ ក៏បានទីសុខស្រួលនៅក្នុងតំណែងថ្មី ។ រឿងពួកនេះមាន « សុជាត » «កូឡាបប៉ៃលិន» «ទូងអាណាជា» ។ល។ រឿងនេះបានឲ្យយើងយល់ថា អ្នកនិពន្ធបំពេអ្នកអានឲ្យយល់ឃើញថា មានតែពួកអ្នកមានធនធាននាយទុនទេ ដែលអាចជួយធុរៈមនុស្សកំសត់ ម្ល៉ោះហើយ គេត្រូវបេះបំរើផ្គាប់ផ្គុនចៅហ្វាយនាយអ្នកមាន ក្រែងមានសំណាងបានធ្វើកូនប្រសា ប្រពន្ធកាន់តំណែងជួស ហើយដល់មានទ្រព្យកាលណាគេក៏ដេកស៊ីជិះឡានដើរលេងមានខ្ញុំបំរើ ។ល។

យើងឃើញមានរឿងម្យ៉ាងទៀត ច្រើនដកទៅរករបៀបបូរាណនិយម ។ គេច្រើនលើករឿងស្តេចក្នុងសម័យបូរាណរួចចម្លងក្បាច់លោកកាប់សម្លាប់ចម្បាំងនៅក្នុងភាពយន្តដែលពួកអាណានិគមនិយមចក្រពត្រូនិយមបារាំង អាមេរិកាំង

បានបញ្ចូលមកបញ្ចាំង ។ សៀវភៅរបៀបនេះមាន «ព្រះមកុដពេជ្រ ព្រះចន្ទរាជា» ។ល។ ។

សៀវភៅ «សង្គ្រាមជានិច្ច» មានដំហានខ្ពស់ជាងពួកប្រលោមលោកឯទៀតក្នុងផ្លូវសង្គម ។ អ្នកនិពន្ធបានផ្ចិតរឿងពិតជាក់ស្តែងច្រើនកន្លែង ក្នុងជីវភាពប្រជាជនពួកបែបង ។ អ្នកនិពន្ធជាអ្នកប៉ិនចំណានមួយ ខាងប្រើប្រយោគវគ្គពាក្យខ្មែរសមល្អ ។ តែអ្នកនិពន្ធនៅយកការយល់សប្តិជាត្រីមុខ ហើយផ្អែកលើកំណាប់ក្នុងរូងឈើ មិនបានចូលជ្រៅទៅមើលស្ថានការណ៍ប្រជាជនពិតប្រាកដ ។

សរុបទៅ សៀវភៅប្រលោមលោកយើងទាំងអស់គ្មានគោលអ្វី ដឹកនាំប្រជាជនឲ្យភ្ញាក់រលឹកទៅរកផ្លូវចំរើនភ្លឺស្វាងទេ ។ សៀវភៅខ្លះ បានប្រែត្រឡប់ថយក្រោយវិញ ទៅរកសរសើររបបសក្តិភូមិនាយទុនទៅវិញ ។ អ្នកនិពន្ធប្រលោមលោកយើង មិនទាន់ដុះលាងស្វាបប៉ាកាឲ្យអស់កំអែលអាណានិគមនិយមចក្រពត្រិ នៅឡើយ ។

ក្រៅពីសៀវភៅប្រលោមលោក យើងមានសៀវភៅមួយផ្នែកទៀត ដែលយើងសន្មតហៅថា «សៀវភៅប្រជាធិបតេយ្យ» ។ រដ្ឋធម្មនុញ្ញនិងអត្ថាធិប្បាយរដ្ឋធម្មនុញ្ញ ជាសៀវភៅច្បាប់ ដែលកើតឡើងក្នុងជំនាន់ក្រោមការត្រួតត្រាអាណានិគមនិយម ។ សៀវភៅនេះ បានចែងទុកឲ្យយើងមានសេរីភាពសិទ្ធិក្នុងការនិយាយក្នុងការសរសេរ ។ តែសេរីភាពសិទ្ធិទាំងនោះ បានត្រូវពួកចក្រពត្តិនិយមរំលាយចោលទៅវិញ ដោយប្រើច្បាប់អយុត្តិធម៌ដាច់ខាតមកវិញ ។

ចំពោះសៀវភៅប្រជាធិបតេយ្យពិត ៗ នេះ យើងអាចរាប់សៀវភៅសិក្សាទាំងប៉ុន្មាន ដែលកើតឡើងក្នុងកម្ពុជា ៨-៩ ឆ្នាំ តស៊ូវាយពួកទមិឡប្រាកដៗ បងប្អូនយើងដែលរួមជាកម្លាំងដែលតស៊ូវាយអាណានិគមនិយមបារាំង ចាប់តាំងពីក្រោយសង្គ្រាមលោកលើកទីពីរលត់ទៅ បានចងក្បួនខ្នាតរៀបរៀងប្រវត្តិសាស្ត្រជាច្រើន ។ យើងសូមស្រង់ឯកសារខ្លះ ។

សៀវភៅ «តស៊ូយូរអង្វែងពិបាក...

ប្រាកដមានជ័យជំនះ» បានរែកញែកបង្ហាញផ្លូវយើងអំពីធម៌សាមគ្គីរវាងប្រជាជនខ្មែរ ព្រមទាំងរែកញែកអំពីហេតុភេទដែលបណ្ដាលឲ្យចក្រពត្តិនិយមបារាំងត្រូវតែបរាជ័យ ព្រោះបំបាំងដែលវាបង្កើតឡើងជាអំពើអយុត្តិធម៌ណាមក ។

សៀវភៅ «ការរំជួលបដិវត្តន៍នៅប្រទេសខ្មែរ» បានបង្ហាញឲ្យយល់ជាក់ថា តាំងពីបារាំងមកប្លន់ប្រទេសយើង ប្រជាជនយើងបានក្រោកតស៊ូជាលំដាប់ ដូចមានរឿងអាចារ្យស្វា, ពោកំបោរ, ស៊ីវត្ថា, អាចារ្យហែម-ចៀវ ។ល។ ហើយនឹងអំពើកលល្បិចហ្វាស៊ីស្តជប៉ុនចង់បង្កើតក្រុម «ផ្កាយខ្មៅ» ហ្វាស៊ីស្តបញ្ចូលប្រទេសយើងឲ្យទៅក្នុងសង្គ្រាមវា ។

សៀវភៅ «អាកប្បកិរិយារៀនសូត្រ» បានពន្យល់យើងឲ្យឃើញថា មានរបៀបរៀនសូត្របីយ៉ាង

១) របៀបចក្រពត្តិនិយមគិតតែខំរៀនចេះ ដើម្បីជិះជាន់ប្រជាជន ។

២) របៀបអនុគុនគឺឃ្មីងឃ្មោង រៀនសម្រាប់ធ្វើនាម៉ឺន

យកបុណ្យសក្តិយសម្តេចក្មេងក្មានបំរើចក្រពត្តិនិយម ។

៣) របៀបវណ្ណៈអធនគឺរៀនដើម្បីដោះទុក្ខអ្នកពលកម្មមានកម្មករកសិករឲ្យចាកផុតអំពីអំពើអយុត្តិធម៌ ។ របៀបរៀនសូត្រ ដើម្បីដោះទុក្ខប្រជាជនទាំងនេះ បានអាចនាំយើងទៅរកផ្លូវយុត្តិធម៌ពិតប្រាកដ ។

សៀវភៅ «ព្យាយាម, សំចៃ, សុចរិត, សម្មាទិដ្ឋិ» ជាសៀវភៅមួយ បានដឹកនាំយើងឲ្យចេះដឹកនាំខ្លួនក្នុងការរៀនសូត្រ ធ្វើការប្រតិបត្តិក្នុងការថែទាំសំចៃសំលៀកបំពាក់ក្រដាស ។ល។

ក្រៅពីសៀវភៅ ដែលមានឈ្មោះខាងក្រោមនេះ យើងអាចឃើញមានសៀវភៅច្រើនទៀត និយាយពីប្រវត្តិប្រជា-ជនខ្មែរតស៊ូក្នុងរវាង ៨-៩ ឆ្នាំ ។ យើងអាចឃើញមាន «ប្រវត្តិរូបអាចារ្យ ហែម-ចៀវ ។ល។ សៀវភៅទុក្ខសកា-សិត» ប្រកាសឯករាជ្យអំពាវនាវប្រជាជនខ្មែរគ្រប់ជាន់ថ្នាក់ឲ្យក្រោកឡើងវាយអាណានិគមនិយមបារាំង នឹងដៃជើងវា ។

សៀវភៅ «មិត្តម្នាក់» បានវែកញែកអំពីដំណើរប្រតិភូខ្មែរ ទៅកាន់ប្រជាជនខ្មែរនៅស្រុកវៀតណាម ហើយចង្អុលថា មានតែប្រជាជនទេ ដែលជាមេកម្លាំងពិត ៗ នៃប្រជាជាតិ

x

x x

**អក្សរសាស្ត្រខ្មែរ ក្នុងសម័យសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ**

ក្រោយដែលបានពិនិត្យមើលអក្សរសាស្ត្រខ្មែរគ្រួសៗ តាំងពីសង្គមសក្តិភូមិ-សង្គមអាណានិគមនិយម (បក្រពត្រ) យើងត្រូវសួរ តើអក្សរសាស្ត្រខ្មែរយើងត្រូវមានចរិតសំខាន់ៗអ្វីខ្លះក្នុងប្រទេសឯករាជ្យសន្តិភាព, ប្រជាធិបតេយ្យ ?

ដំបូងយើងត្រូវបដិសេធគំនិតយល់ខុសថា: «សិល្បៈសម្រាប់តែសិល្បៈ» ឬ «កំណាព្យសម្រាប់កំណាព្យ» ឲ្យជ្រះស្រឡះ ព្រោះដូចយើងបានរែកញែកមើលអក្សរសាស្ត្រខ្មែរមកហើយ សិល្បៈឬកំណាព្យសុទ្ធតែកើតឡើងពីមនុស្ស ហើយសម្រាប់ក្រុមមនុស្សណាមួយជាដាច់ខាតៗ ច្បាប់ក្រម ច្បាប់

ស្រីកើតឡើងសម្រាប់សង្គមសក្តិភូមិ ។ «គតិលោក» ក៏បានកើតឡើងក្នុងសម័យអាណានិគមនិយមហើយក៏ស្របទៅតាមរបបនោះឯង ។

ប្រទេសខ្មែរយើងសន្តិភាពឯករាជប្រជាធិបតេយ្យ ត្រូវតែមានអក្សរសាស្ត្រសម្រាប់សម័យប្រជាធិបតេយ្យនេះដែរ ។ មុននឹងនិយាយ តើអក្សរសាស្ត្រយើងត្រូវមានចរិតប៉ុន្មាន យើងសូមលើកពាក្យអ្នកប្រាជ្ញខ្លះមកជូនពិចារណា ។ អ្នកប្រាជ្ញចំណានម្នាក់បាននិយាយថា: «អ្នកទស្សនៈវិជ្ជា មិនគ្រាន់តែចម្លងហេតុការណ៍ដែលមាននៅក្នុងសង្គមប៉ុណ្ណោះទេគឺអ្នកនិពន្ធត្រូវរកមធ្យោបាយ ដឹកនាំសង្គមឲ្យបានដើរទៅរកផ្លូវចំរើនយុត្តិធម៌» ។

ដូចសេចក្តីខាងលើនេះ អ្នកនិពន្ធត្រូវ... បង្ហាញផ្លូវដើរឿនលឿនចំរើន... អ្នកនិពន្ធត្រូវលើកតម្កើងគុណសម្បត្តិប្រសើរ ៗ នៃប្រជាជនទៅវិញមុខ មិនត្រូវមានតែចម្លងផ្តិតត្រង់សកម្មភាព ពុករលួយ

នៃសង្គមក្រុមក្រោមទេ ។ ដើម្បីនឹងឲ្យស្គាល់ការតស៊ូយុត្តិធម៌ប្រជាជន អ្នកនិពន្ធត្រូវដាក់ខ្លួនជាប្រជាជន មិនត្រូវគ្រាន់តែចង្អើតឈោងមើលពីលើតែប៉ុណ្ណោះឡើយ ។ អ្នកនិពន្ធត្រូវសរសេររឿងមានលក្ខណៈប្រជាជាតិ ប្រជាជននិងវិទ្យាសាស្ត្រ ។

«ប្រជាជាតិ» បានសេចក្តីថា យើងត្រូវលើករឿងដែលមានចរិតប្រជាជាតិខ្មែរពិតៗ ។ ធម្មតាជាជាតិនានា មិនមានចរិតភាគច្រើយាននឹងទេសភាព ដូចគ្នាទាំងអស់ទេ ។ អក្សរសាស្ត្រយើង ត្រូវដើរតាមលំនាំជានអក្សរសាស្ត្រជាន់មុនៗជៀនលៀនមានរឿងព្រេងជាដើម ។

«ប្រជាជន» បានសេចក្តីថា យើងលើកប្រជាជនជាធំៗ អ្នកតំរូវឯករបស់រឿងយើងទាំងប៉ុន្មាន គឺប្រជាជនកម្មករកសិករ អ្នកធ្វើការ ។ យើងមិនត្រូវដើរតាមដានរឿងសាស្ត្រល្បែងបុរាណប្រលោមលោកសម័យមុនជិតៗ នេះឡើយ ។ យើងត្រូវបន្តអក្សរសាស្ត្រប្រជាជនយើងមានអាឡូវ ចេញ

ជ័យ សុភាពនិរាយ ។ល។ តែយើងត្រូវផ្ដាផ្លូវយុត្តិធម៌ ។
ប្រជាជនដើរទៅបានសុខសម្បូណ៌ ។ គុណវិបត្តិនៃរឿងព្រេង
ប្រជាជនយើងសម័យសក្តិភូមិ គឺចេះតែត្អូញត្អែរទ្រាំ តែមិនចេះ
បង្ហាញផ្លូវយុត្តិធម៌ ព្រោះសម័យនោះការចេះដឹងយល់ឃើញ
នៅស្ដួចស្ដើងណាស់ ។

ម្យ៉ាងទៀតប្រយោគឃ្លា របៀបសរសេរ យើងត្រូវ
សរសេរឲ្យប្រជាជនងាយយល់ៗ យើងត្រូវបញ្ចាំងក្នុងរឿងការ
តស៊ូប្រជាជនទល់នឹងធម្មជាតិ ការតស៊ូស៊ូតស្វាញប្រជាជន
ដើម្បីសិទ្ធិសេរីភាព សន្តិភាពប្រជាធិបតេយ្យ ។

«វិទ្យាសាស្ត្រ» បានន័យថា អក្សរសាស្ត្រយើង ត្រូវ
ផ្អែកទៅលើការជាក់ស្តែង យើងជម្រុសចោលនូវជំនឿគ្មាន
សមះហេតុសមផល ។ យើងត្រូវផ្អែកលើវិទ្យាសាស្ត្រព្រោះ
មានតែវិទ្យាសាស្ត្រទេ ដែលអាចសម្រួលកម្លាំងប្រជាជន
យើងក្នុងការបង្កើតផលិតផល ហើយនឹងកាបង្ស៊ះយើងចាក
ផុតពីជំនឿគ្មានសមហេតុសមផល ។

—ចប់—

## ឧបសម្ពន្ធ

# ប្រវត្តិសង្គមមនុស្ស

ផែនដីយើងកាលពីដើម ជាដុំភ្លើងវិលជានិច្ច ។ យូរមកដោយការប្រែប្រួលនៃធាតុធម្មជាតិផ្សេងៗ ដុំភ្លើងនោះបានត្រជាក់ ។ រុក្ខជាតិសត្វតូចធំ.ចាប់ផ្ដើមមានជីវិតឡើង ។ តមកទៀត មនុស្សក៏បានកើតឡើងដែរ ។ តាំងពីមានមនុស្សមក គេឃើញមានសង្គមមនុស្សវិវត្តន៍ពីទាបទៅខ្ពស់ជាលំដាប់ សង្គមសមុហភាពបុព្វកាល, ទាសភាព, សក្តិភូមិ, ទុននិយម សង្គមនិយម ។

១–សង្គមសមុហភាពបុព្វកាល–ដើមឡើយមនុស្សរស់ដោយសារធម្មជាតិ ដើរបេះផ្លែឈើចិញ្ចឹមជីវិត ហើយទៅណាមកណាទៅតាំងហ្វូងៗ ។ ក្នុងការតស៊ូទល់នឹងធម្មជាតិ

សម័យនោះ មនុស្សចេះសាមគ្គីស្រឡាញ់គ្នាជាពន់ពេក គំនិតបោកជិះជាន់គ្នាពុំទាន់កើតមានឡើយ ។

## ២- សង្គមទាសភាព – ក្នុងការបង្កើនផល (ការងារ)

មនុស្សបានរកឃើញមធ្យោបាយជាច្រើន ហើយបានចេះកាប់គាស់ចំការចិញ្ចឹមសត្វត្រួតត្រាធម្មជាតិបានខ្លះ ជាហេតុផ្ដើមការរកស៊ីរស់នៅប្លែកៗគ្នា មានខ្លះខ្លាំងពូកែ ដើរកំហែងអ្នកទន់ខ្សោយឲ្យគេប្រយោជន៍ខ្លួន ។ ក្នុងសង្គមនេះគេឃើញ :

ក) ការបង្កើនផលិតកម្ម: ចេះចិញ្ចឹមសត្វកាប់គាស់ទីដីកម្លាំងមនុស្សផ្ទាល់ ។ ផលិតកម្មនៅខ្សោយ ។

ខ) ការចាត់ចែងផលិតកម្ម: (មនុស្សនិងមនុស្ស)ឬបែងចែកផលិតផលមិនបានស្មើគ្នាទេ ។ ខ្ញុំកំដរឬទាសាធ្វើការចិញ្ចឹមចៅហ្វាយម្ចាស់ ។ មានការជិះជាន់គ្នា ការទំនាស់វណ្ណៈរវាងខ្ញុំកំដរនិងចៅហ្វាយម្ចាស់ ។

## ៣–សង្គមសក្តិភូមិ

ក) ការបង្កើនផលិតកម្ម: ឧស្សាហកម្មគ្រួសារ ត្បាញ ភ្ជួររាស់នឹងនង្គ័ល រនាស់ បានចំរើនជាងសម័យទាសភាព ។

ខ) ការទាក់ទងផលិតកម្ម: ស្តេចត្រាញ់ (សក្តិភូមិ) បង្ខំឲ្យអ្នកងារកសិករ ធ្វើការ ធ្វើស្រែឲ្យខ្លួន ៗ មានការទំនាស់វណ្ណៈទៀត រវាងសក្តិភូមិនឹងអ្នកងារ ។

## ៤–សង្គមទុននិយម

ក) ការបង្កើនផលិតកម្ម: ឧស្សាហកម្មធំៗ រោងចក្រមនុស្សប្រើកម្លាំងម៉ាស៊ីនត្រួតធម្មជាតិ;

ខ) ការទាក់ទងផលិតកម្ម: នាយទុនប្រមូលយកផលតែម្នាក់ឯង ជិះជាន់កម្មករឲ្យរងទុក្ខវេទនា ។ មានការទំនាស់វណ្ណៈរវាងនាយទុននឹងកម្មករ ។

# ៥- សង្គមនិយម

ក) ការបង្កើនផលិតកម្មៈ ឧស្សាហកម្មធំៗកើនចក្រ មនុស្សបង្កើតតិកនិកថ្មីៗ ត្រួតត្រាធម្មជាតិ ។

ខ) ការចាត់ចែងផលិតកម្មៈ បែងចែកឲ្យមកអ្នកធ្វើការទាំងអស់គ្នា ផ្អែកទៅលើគោលការណ៍ «ម្នាក់ៗត្រូវឲ្យទៅសង្គមតាមសមត្ថភាពរៀងៗខ្លួន ហើយសង្គមសងមកវិញ តាមការងាររួចតាមសេចក្តីត្រូវការនៃម្នាក់ៗ» ។

ការវិវត្តន៍សង្គមពីទាបទៅខ្ពស់នោះ បានជួបប្រទះការថ្នាំងថ្នាក់ជាច្រើន ជៀសវាងការបដិវត្តន៍មិនបាន ។

ការបដិវត្តន៍ ឆ្នាំ ១៧៨៩ រំលាយរបបសក្តិភូមិនៅស្រុកបារាំង ។ល។

# បញ្ជីរឿង

ទំព័រ


អារម្ភកថា - - - - - - - - - - - - - - - ក
ប្រវត្តិកំណើតអក្សរសាស្ត្រ - - - - - - - - ១
អក្សរសាស្ត្រខ្មែរ - - - - - - - - - - ៥
អក្សរសាស្ត្រសម័យអង្គរ - - - - - - - - ១៧
អក្សរសាស្ត្រក្រោយសម័យអង្គរ ឆ្លងតាមលង្វែក
មកឧត្តុង្គរជ្ជកាលព្រះអង្គឌួង - - - - - - ២២
ក) របៀបសិក្សា - - - - - - - - - - ២៣
ខ) គ្រូអាចារ្យ - - - - - - - - - - ២៤
គ) កម្មវិធី - - - - - - - - - - - - ២៥
អក្សរសាស្ត្រចែកជាបង្កោមធំពីរ - - - - - ២៨
អក្សរសាស្ត្របដិកិរិយា - - - - - - - ២៩
ក) រឿងសាសនា - - - - - - - - - - ៣០

ទំព័រ


ខ)- ច្បាប់ក្រមប្រុស ស្រី - - - - - - - - ៣០

គ)- ច្បាប់កឹងកៃស្ត្រី - - - - - - - - -៣២

ឃ)- ស្ត្រាំល្បើ - - - - - - - - - ៣៣

ង)- រឿងទាវ-ឯក - - - - - - - - - - ៣៧

រឿងទាវ-ឯករបស់លោកប៉ុលសេនា ទូ-កន - - - ៤៤

អក្សរសាស្ត្រប្រជាជន - - - - - - - ៥០

ក) រឿងពេងប្រឆាំងពេញទំនងការបន់ស្រន់ថាមាន

អ្នកតា - - - - - - - - - - - ៥២

ខ) រឿងព្រេងប្រឆាំងនឹងមន្តគាថា - - - - - - ៥៤

គ) រឿងព្រេងប្រឆាំងរបបសង្គមផាប់ខ្ទុកក្មេក - - ៥៥

ឃ) រឿងអាឡេវ - - - - - - - - - - ៥៦

ង) រឿងធ្មេញជ័យ - - - - - - - - - - ៥៩

ច) រឿងសុភាទន្សាយ - - - - - - - - - ៦៣

ទំព័រ

អក្សរសាស្ត្រខ្មែរក្រោមនឹមដែកអាណានិគមនិយម
ប៉ារាំង ១៩៤៥ . . . . . . . ៧០

១) បង្កើតសាលាបាលី . . . . . . . . ៧២

២) ក្តាប់បណ្ឌិតអក្សរសាស្ត្រខ្មែរ . . . . . . [illegible]

ទោះក្នុងរបបអាណានិគមនិយមអក្សរសាស្ត្រខ្មែរ

សាបសូន្យ . . . . . . . . . . . . ៧៦

គតិលោក . . . . . . . . . . . . . ៧៧

ច្បាប់ក្រមង៉ុយ . . . . . . . . . . . ៨០

អក្សរសាស្ត្រខ្មែរក្រោយសង្គ្រាមលោកលើកទីពីរ ៩

អក្សរសាស្ត្រខ្មែរសម័យឯករាជ្យប្រជាធិបតេយ្យ ៩០

—០០០—

ឧបសម្ព័ន្ធ

ប្រវត្តិសង្គមមនុស្ស . . . . . . . . ៩៥

ផ្សារនិងព្យួរខ្មែរ
BAYON
MARKET & GIFT SHOP
A Khmer Arts Center
1161 E. 10th St., Long Beach, CA 90813
Tel. (213) 599-3120 • Fax. (213) 599-2337

$ 1000